# សៀវភៅសិក្សា

ហ៊ុន គឹមសៀ

# មូលដ្ឋាន
# ដើម្បីយល់អក្សរសាស្ត្រ

## ជាជំនួយដល់ការពិចារណា




## សំរាប់អ្នកសិក្សាទូទៅ

CA 28

# សៀវភៅសិក្សា

ហ៊ុន - គមសៀ

## មូលដ្ឋាន

# ដើម្បីយល់អក្សរសាស្ត្រ

ជាជំនួយដល់ការពិចារណា . . .

ការផ្សាយរបស់
បណ្ណាគារភ្នំពេញ
លេខ ៥៩ វិថីបាស្ទ័រ ភ្នំពេញ

ព.ស. ២៥០៧ - គ.ស. ១៩៦៣

(បណ្ណាគារភ្នំពេញរក្សាសិទ្ធិ)

# អារម្ភកថា

មានមិត្រសំឡាញ់ក៏ដូចជាសិស្សានុសិស្សភាគច្រើនបានត្អូញ
ត្អែរសួរយើងខ្ញុំថា ៖ «ក្នុងការរៀនអក្សរសាស្ត្រមានជួបប្រទះនឹង
ការលំបាកច្រើន បែបគោលក្រិតាំងនាំឲ្យធុញ ហើយរៀនមិនសូវ
យល់ ...» ។

និយាយរួម តាមការពិនិត្យរបស់យើងខ្ញុំក៏យល់ឃើញបាន
ថាប្រភពនឹងលក្ខណៈបែបខាងលើនោះមែនពិតដែរ. ពីព្រោះ
យើងមិនទាន់ធ្លាប់.. ប៉ុន្តែយើងខ្ញុំសុំមានយោបល់ដូចតទៅនេះ៖

ហេតុអ្វីបានជារៀនមុខវិជ្ជាអក្សរសាស្ត្រនេះតែបែបគោល
តាំង ... តើមុខវិជ្ជានេះជាគោលក្រិតាំងដូចជាយើងបានប្រទះ
មែនឬទេ ?

បុរាណនិយាយថា «ខ្លាចយូរទៅៗជាធ្លាប់ ធ្លាប់យូរទៅៗ
ជាធម្មជាតិ (ធម្មតា)» ។ ពិតមែនណាស់ ការក្រចំពោះអ្នក
ធ្លាប់ទៅជាងាយ ការសម្លាយចំពោះអ្នកមិនធ្លាប់ទៅជាលំបាក ។
មុខវិជ្ជាអក្សរសាស្ត្រក៏ជាមុខវិជ្ជាមួយ ដូចគ្នានឹងមុខវិជ្ជាដទៃទៀត

ដែលយើងកាលគ្នាជាប់ជាងរៀនកន្លងមកអំពីនដែរ ហើយមុខវិជ្ជានេះ ក៏វិវត្តទៅរៀងរៀងទៅតាមសន្ទុះនៃអត្ថភាពសង្គម (Existence sociale) មនុស្សថែមទៀតផង (ខនេះគុសបញ្ជាក់ឲ្យឃើញថា អក្សរសាស្ត្រក៏មានបរិតដូចគ្នានឹងមុខវិជ្ជាដទៃ ) ហេតុនេះ រូបយើងនិមួយៗ ដែលជាសមាសភាព ជាពុម្ពភា យើងក៏គួរតែបានយល់ បានបេះដឹងនូវមុខវិជ្ជានេះជាចាំបាច់ ទោះតិចឬច្រើនយ៉ាងម្ដេច ។

ក្នុងការសិក្សាលើកដំបូងដោយប្រៀបធៀប ទោះបីយ៉ាងណាក៏ដោយយើងក៏ត្រូវតែជួបប្រទះនឹងការលំបាក ... ដូចជាមានពាក្យថ្មី អត្ថន័យទូលាយមានសារសុីជម្រៅស្រាវជ្រាវរកឫសគល់ ដើម្បីយើងឡើងទៅដល់ចុងបាន ទោះបីជាមុខវិជ្ជាណាក៏ដោយ នេះយើងមិនទាន់និយាយដល់មុខជំនាញនឹងសិល្បៈលាក់ត្រដាងក្នុងការពន្យល់ប្លែកៗគ្នា នៃអ្នកបង្រៀនថែមទៀតផង ។

ឧបមាដូចជាយើងចាប់ផ្ដើមរៀនអក្សរ មុនដំបូងយើងគឺត្រូវតែរៀនតួព្យញ្ជនៈឲ្យចាំស្ទាត់ .. ស្រៈ ... ប្រកបអំពីនដែរ ដល់កាលណាយើងចេះពាក្យមួយចំនួនជាចាំបាច់ហើយ ទើបយើងកាន់សៀវភៅបាន យល់អត្ថសំខាន់ ដូចគោក ក្រខាំង ដាក់ឃើញអក្សរបែបដូចព្រៃឈើដាក់ទុកព្រាត់ហើយ ក្រឡប់ទៅជាចូលចិត្តវិញ ...។ ហេតុនេះ ការរៀនអក្សរសាស្ត្រក៏ដូច្នោះដែរ គឺជាមុនដំបូងយើងក៏ត្រូវតែយល់ឲ្យបានច្បាស់នូវវិធាន (loi) នៃអក្សរសាស្ត្រ បន្ទាប់មកយើងត្រូវសិក្សាស្រាវជ្រាវរឿនអក្សរសាស្ត្រជាតិ អន្តរជាតិ (ឲ្យបានបើកគំនិតគិតដើម្បីប្រៀបធៀប) តាមសម័យ តាមកាលៈទេសៈនីមួយៗ ដើម្បីឲ្យយល់នូវព្រឹត្តិការណ៍ផ្សេងៗ ។ ប្រែប្រួលទៅក្នុងរដ្ឋ បន្ទាប់ពីសម័យនីមួយៗ ការប័ត្តនយោបាយសេដ្ឋកិច្ច ប្រៀបធៀប ការចលាចល ការធ្លាក់ចុះអន់ថយ ឬការរុងរឿងជឿនលឿនជាដើម ...។

និយាយសង្ខេបទៅគឺថា ៖ កាលណាយើងយល់បានច្បាស់នូវវិធានដែលជាមូលដ្ឋាននៃអក្សរសាស្ត្រហើយ យើងក៏អាចយល់បាននូវបាតុភូតនៃអក្សរសាស្ត្រ យើងក៏អាចរកឃើញនូវមូលហេតុដែលជាកត្តានៃការវិវត្តន៍ ឬវិបត្តិមួយតាមវិស័យអក្សរសាស្ត្រ ... បន្ទាប់មកទៀតយើងនិយាយដល់ការស្ទាក់ជំទាញប៉ុនប្រសប់បាត់ពុញទ្រាន់ ដូចកាលយើងទៀបចាប់ផ្តើមសិក្សា ។

ការសិក្សាអក្សរសាស្ត្រ អាចបំភ្លឺឲ្យយើងឃើញបាននូវ-ប្រព័ន្ធអក្សរសាស្ត្រ (Système littéraire) មួយដែលមានមូលដ្ឋានគោរមាននៅក្នុងលក្ខណៈមួយ ហើយក៏វិវត្តន៍តាមកាលៈទេសៈមួយព្រមទាំងអនុលោមទៅតាមករណីយ៍ជាក់ស្តែង នៃសង្គមរបស់ប្រទេសនីមួយៗ ... ។ល។

វិជ្ជាអក្សរសាស្ត្រអាចជួយយើងឲ្យមើលឃើញការលូត-លាស់រីកចំរើនឬការអន្តរាយអាប់អោនដល់កិរិតណាមួយ ដែលសង្គមមនុស្សបានជួបប្រទះក្នុងអតីតកាល ទុកជាមេរៀនរកផ្លូវល្អ

ទៅអនាគត ដែលជាលទ្ធផលនៃបច្ចុប្បន្នដែលយើងត្រូវតែដោះស្រាយក្នុងការអនុវត្តន៍ ។

ក្នុងសៀវភៅនេះ យើងមានលោកគ្រូជាច្រើនរៀនអក្សរសាស្ត្រនៃជាតិដែលខ្ញុំទុកជាមូលដ្ឋានទាំងគំនិតក្នុងការស្រាវជ្រាវស៊ើបស្រាវនិងរបៀបរៀប ដើម្បីកែយកនូវអក្សរសាស្ត្រ ឬ ខឿនវប្បធម៌ និយាយរួមនៃជាតិខ្មែរ ... ។ ពីព្រោះថា «គេមិនអាចជឿបានថាមហាសាគរកំពុងគ្មានទេ ក្នុងពេលដែលគេមិនទាន់បានឃើញ ឬ បានជិះអំពីទន្លេ» ។

យើងសុំសរសើរលោកនាយកវិទ្យាល័យ កំមានកាស, ដោយលោកខំប្រឹងយកចិត្តទុកដាក់ជួយយោបល់ដល់យើងក្នុងវិស័យនេះ, គឺដូចជាសហប្រតិបត្តិការរបស់លោកជាច្រើនទៀតក្នុងការជួយស្រាវជ្រាវកែមូលដ្ឋានអក្សរសាស្ត្រ នៃ ជាតិមួយដែរ ។

ថ្ងៃ១៥-៣-៦៣

ហ៊ុង - គីអាសៀ

គ្រូបង្រៀនអក្សរសាស្ត្រ នៅវិទ្យាល័យកំមានអាកាស

# អ្វីដែលហៅថាភាសា?

ភាសា គឺជាពាក្យសំដីដែលមនុស្សនិយាយជាសំឡេងចេញមកក្រៅ ឬថាភាសា គឺជាឧបករណ៍១យ៉ាងដែលមនុស្សសម្រាប់ប្រើជាមធ្យោបាយដើម្បីលាតត្រដាងនូវមនោសញ្ចេតនា, គំនិត, សតិអារម្មណ៍ ... ក្នុងការទាក់ទងគប់រកគ្នា ឲ្យយល់គ្នាទៅវិញទៅមកដោយសំដី (ភាសា) ។ និយាយមួយបែបទៀតថា: ភាសាគឺជាបាតុភូត (phénomène) នៃសង្គមមនុស្ស ភាសាកកើតឡើងពីសេចក្តីត្រូវការរបស់មនុស្សរស់នៅក្នុងសង្គម ការបញ្ចេញសតិអារម្មណ៍ គំនិតស្មារតី... ឲ្យគ្នាទៅវិញទៅមកក្នុងដំណើរចលនាធ្វើពលកម្ម ដើម្បីចិញ្ចឹមជីវិត ។ បើគ្មានភាសា មនុស្សមិនអាចមានផលិតផល គ្មានការរីកចំរើនឡើងៗ ។ និយាយរួមទៅ គឺជាគ្មានទាំងសង្គមមនុស្សថែមទៅទៀតផង ។

ទាក់ទងយ៉ាងជិតស្និទ្ធនឹងសតិអារម្មណ៍ (គំនិត) ភាសាអាចគេស្គាល់ចំណាំក្នុងពាក្យសំដីនូវបណ្ដាលទុកផល នៃការចលនារាងស្មារតី រាល់ការចំរើនឡើងៗរបស់មនុស្សក្នុង

ឱ្យយល់បាននូវរឿងវប្បធម៌ របស់ជាតិយើង និងជាតិនានា ដែលមានទាក់ទងដល់គ្នា ក៏មានសារៈសំខាន់ណាស់ ។

ក្នុងការស្រាវជ្រាវមូលដ្ឋាននៃអក្សរសាស្ត្រ ឬ វប្បធម៌ជាតិ និយាយរួម ក្នុងការស៊ើបជ្រាវឲ្យយល់បានច្បាស់ហើយត្រឹមត្រូវ ផងនូវគោលខ្លឹមសារនៃអក្សរសាស្ត្រជាតិ ក្នុងការណែនាំ ទស្សនៈរបស់ខ្លួនឲ្យមានសុគតិជ័យ មានគំនិតត្រឹមត្រូវ ជាសត្យានុមត (objectif) ឬក៏បណ្តោយតាមគតិបណ្ឌិតខាងការវាយថ្លៃអក្សរសាស្ត្រ ឬ វប្បធម៌ជាតិយើង យើងគ្នាគ្រប់ៗ សម្រេចយល់ឲ្យបាននូវរឿងអក្សរសាស្ត្រ ឬ វប្បធម៌នៃជាតិដទៃពីបុចថែមទៀត ក្រៅពីជាតិយើង ដើម្បីជាគតិណាក្នុងការប្រៀបធៀប ។

ពីព្រោះហេតុអ្វី បានជាយើងចង់យល់ឲ្យបានច្បាស់នូវ<u>រឿងអក្សរសាស្ត្ររបស់ជាតិយើង ហើយគួរតែត្រូវឲ្យដឹងអក្សរសាស្ត្រ ឬ វប្បធម៌ជាតិដទៃផង ?</u> ពីព្រោះថា : ក្នុងការស៊ើបជ្រាវ ការយល់ ការដឹងឲ្យបានច្បាស់លាស់ ហើយត្រឹមត្រូវនេះ

ខ្ទង់ខៀនកម្ពុជា ខ្ទង់ខៀនអក្សរសាស្ត្រនិយាយដោយខ្មែរ យើងចង់យកតម្លៃវិទ្យាសាស្ត្រសមកម្ម (កុំឱ្យទាបពេក កុំឱ្យខ្ពស់ពេក) យើងត្រូវការធ្វើការប្រៀបធៀប ។

មានយោបល់ខ្លះឆ្លើយថា : «ពុំចាំបាច់ ប្រៀបធៀបទិនអក្សរសាស្ត្រ ឬ វប្បធម៌ជាតិដទៃធ្វើអី ប្រៀបធៀបតែជាមួយទិន្នជាតិយើងទៅបានហើយ គឺថាអក្សរសាស្ត្រណាក៏ល្អគ្រាន់ត្រូវតែកើតលើជាតិនោះ កំដើរស្របទិន្នភាពជាតិនោះៗ . . . » ។

យើងមានយោបល់ឆ្លើយថា: ការប្រៀបធៀបតាមយោបល់ខាងលើនេះក៏ល្អមែនហើយ គឺថា : អក្សរសាស្ត្ររបស់ជាតិណាមួយក៏: ជាងតែបំពេញប្រយោជន៍ជាតិនោះ នោះគ្រប់វិស័យណាក៏ដោយ នោះគិតច្រើន...។ ប៉ុន្តែបើយើងសួរថា: អក្សរសាស្ត្រជាតិនោះកំបំពេញប្រយោជន៍របស់ជាតិនោះបានដល់កំរិតណាឬតម្លៃអក្សរសាស្ត្ររូបភាព តម្លៃសតិស្មារតីក្នុងកាលៈទេសៈមួយជាជាក់លាក់ គេកាន់បានដល់កំពស់ណាដែរ ? ចំលើយគឺគិត,

កំពស់, បរិមាណ ... នៃការចំរើនរបស់អក្សរសាស្ត្រ ចំពោះផលប្រយោជន៍ជាតិយើងត្រូវការ ធ្វើការប្រៀបធៀបរកអក្សរ-សាស្ត្រជាតិមួយទៅនឹងជាតិមួយទៀតតាមជាបទាត ;

ឧទាហរណ៍ - បើសិនជានៅលើលោកនេះមានតែមនុស្សម្នាក់ តើមនុស្សនោះគាប់ជនបានថាខ្លួនគាត់ជាអ្វីខ្លះ? តើគាត់កើតដឹងជារូបគាត់នេះជាភេទប្រុសឬស្រីទេ? តើគាត់មានឈ្មោះសម្រាប់ហៅឬទេ? តើគាត់ដឹងថាគាត់ជាជាតិអ្វីទេ? ... ។ល។ ទេ ! ប្រហែលជាគ្មានបានគុំគិតបែបនេះទេ បើយើងនិយាយឲ្យកប់ទៅ ។ និយាយមួយបែបទៀតថា : មនុស្សដឹងបានថាមានភេទប្រុសមកអំពីមានភេទស្រី, ដឹងថាខ្លួនមានទ្រព្យមកអំពីមានអ្នកក្រទ្រព្យ ដឹងថាអក្សរសាស្ត្ររបស់យើងល្អនឹងប៉ិនមកអំពីមានអក្សរសាស្ត្រជាតិដទៃទាបទន់ខ្សោយ... ។ល។

មុននឹងនិយាយអំពីអក្សរសាស្ត្រ យើងចាំបាច់គប្បីគួរបានយល់ អំពីបញ្ហាកាតកសាស្ត្រជាមុនសិន ពីព្រោះជាបញ្ហាចាំបាច់

ពីរនេះទាក់ទងគ្នាយ៉ាងជិតបិតណាស់ និយាយមួយបែបទៀតថា៖ ភាសាសាស្ត្រនិងអក្សរសាស្ត្រជាគូគ្នា ។ អក្សរសាស្ត្រតែងយកអក្សរជាសញ្ញាសំគាល់ ចំណែកឯភាសាសាស្ត្រវិញគឺគេយកសំឡេងជាសញ្ញាសំគាល់ ហើយម្យ៉ាងទៀត អក្សរសាស្ត្រចាប់ផ្តើមមានរូបរាងចេញមកក្រោយភាសា ពីព្រោះហេតុនេះហើយបានជាយើងត្រូវតែដឹងភាសាសាស្ត្រជាមុន ។

# អ្វីគឺជាអក្សរសាស្ត្រ ?

សម័យនេះ ស្ថានសិក្សា ឬ ជាពិសេសករណីរៀនសូត្រអក្សរ
សាស្ត្រជាតិ ដោយប្រៀបធៀបទៅគឺមានសន្ទុះលឿនទៅមុខ
យ៉ាងខ្លាំង មិនតិចឡើយ តែចំពោះសិក្ខាកាមដែលជាអ្នកមានករ-
ណីយកិច្ចត្រូវតែសិក្សារៀនសូត្រទៅតាមសាលានានា, សូម្បីតែ
មហាជនសាមញ្ញនៅតាមជនបទថ្មីកាត់មាត់ញកនិយាយរួម...
ក៏មានបំណងចង់ចិត្តនឹកឃើញការរៀនសូត្រ, បេះគៀនផ្លាស់
ព្រមទាំងត្រូវការចង់ចេះដឹងដែរ. នេះយើងមិនទាន់និយាយដល់
រំពឹងសំណាក់អស់លោកអ្នក សាស្ត្រាចារ្យ បង្ហាត់បង្រៀនដ៏ច្រើន
ដែលសំរេចយកចិត្តទុកដាក់ដាំដែកវែកញែកគ្នា ជេញជោលកេបូស
គល់ទុកជាគសិណា ស្រាវជ្រាវរកឯកសារផ្សេង ១ ដែលជាគស្តុ-
តាំងសម្ភារៈនៅកប់សម្ងំក្នុងសារមន្ទីរនានា មានវត្តអារាម សិលា
ចារឹក ប្រាសាទពីបូកណដែលនៅកប់ក្នុងព្រៃព្រឹក្សលើគំនូរដែនបទ
នោះៗ ដែលទៀតផង... ។ល។ ហេតុដូច្នេះយើងគាប់សន្និដ្ឋាន
បានថា: នាទីអក្សរសាស្ត្រក្នុងសម័យបច្ចុប្បន្ន ទាំងការស៊ីជម្រៅ

វិស័យត្រិះរិះនិងការពិចារណា ។ បើគ្មានភាសា សតិអារម្មណ៍របស់មនុស្សមិនអាចមាន (Exister) និងរីកចំរើនរហូតមកដល់សព្វថ្ងៃនេះបានឡើយ ។

តាមអត្ថរូបនិងអត្ថន័យរបស់វា ភាសាក៏គ្មានបែងចែកវណ្ណៈ ឬរើសអើងជាន់ថ្នាក់ (Distinction) មនុស្សទេ ភាសាក៏ជារបស់មនុស្សទាំងមូលដែលមានរស់នៅក្នុងសង្គម ពីព្រោះភាសាក៏ជាមរតកនៃមនុស្សទាំងអស់គ្នា ភាសាក៏ជាមធ្យោបាយរបស់មនុស្សក្នុងការទាក់ទងគ្នាមិនថាវណ្ណៈណា ឬមនុស្សក្នុងជាន់ថ្នាក់ណាទេ ។ ប៉ុន្តែផ្ទុយទៅវិញ មនុស្សដែលរស់នៅក្នុងវណ្ណៈខុសគ្នាត្រឡប់ជាយកចិត្តទុកដាក់ដល់ភាសា សំគាល់ពិចារណានិងត្រិះរិះចំពោះភាសា ហើយខំប្រឹងកែច្នៃយកភាសាដែលជាមរតករួមរបស់មនុស្សនោះ ទៅបំរើផលប្រយោជន៍របស់វណ្ណៈរៀងៗខ្លួនទៅវិញ ..ហេតុនេះហើយបានជាគេឃើញមានកើតជាពាក្យខុសៗគ្នាតាមតំបន់ មានទំនៀមទម្លាប់ពាក្យនិងពាក្យផ្សេងៗតាមពួកតាមក្រុមដោយច្បាស់លាស់ ។

យើងទាំងអស់គ្នាបានឃើញនិងបានយល់ ហើយនូវបញ្ហាភាសាខាងអត្ថន័យ និងអត្ថរូបព្រមទាំងគុណប្រយោជន៍របស់វា ចុះចំណែកឯអក្សរសាស្ត្រវិញ តើក៏មានអត្ថរសនិង នាទីផ្សេងខុសគ្នាយ៉ាងណាទៅដែរ . . . ?

ការពិតភាសានិងអក្សរក៏មិនខុសគ្នាប៉ុន្មានទេ ខាងមូលដ្ឋាន : ដូចយើងបានអធិប្បាយមកខាងលើស្រាប់ហើយថា : ភាសាគេយកសំឡេងនិយាយជាសញ្ញា ចំណែកឯអក្សរវិញគេយកគំនូសជាសញ្ញា ហេតុនេះក៏មានការខុសគ្នាបន្តិចតែត្រង់រូបភាពហើយនិងគុណធម៌ខ្លះៗ ដូចជាការរក្សាពាក្យសំដីឲ្យបានយូរអង្វែងមិនរលួយពីសតវត្សរ៍មួយទៅសតវត្សរ៍មួយទៀត ដោយមិនបាច់ត្រូវការមនុស្សជួបគ្នាផ្ទាល់បាន ... ?

អត្ថន័យ — ពាក្យថាអក្សរសាស្ត្រនេះ ក៏មានន័យចម្រុះយ៉ាងទូលំទូលាយមានបរិគុណទាំងហើយគំនិតណែនាំអក្សរសាស្ត្រឲ្យស្របទៅតាមវិធីក៏មានការខុសគ្នាទៅតាមទស្សនការរបស់អ្នក

ដឹកនាំដែលមានសេចក្ដីប្រាថ្នាជាគោលបំណងខុសៗ គ្នាថែមទៅទៀត ។

គំនិតអ្នកខ្លះ ណែនាំអក្សរសាស្ត្រជូនទៅខាងសិល្បៈពេក អ្នកខ្លះជូនទៅខាងចរិយាពេក អ្នកខ្លះទៀតជូនទៅខាងនយោ-បាយពេក.. ហេតុនេះហើយបានជាគេឃើញអក្សរសាស្ត្រក្នុងពេលនេះប្រែក្លាយខ្លួនទៅជាឧបករណ៍មួយ សម្រាប់ឃោសនាបលតាមមហាជនឲ្យធ្វើការអ្វីមួយតាមគោលបំណងរបស់ខ្លួន ដែលគិតឃើញ... ដូច្នេះយើងអាចសន្និដ្ឋានបានថា : អក្សរសាស្ត្រជាសភាវៈគ្មានស្មារតី ប៉ុន្តែមានរូបភាពពណ៌សម្បុរអនុលោមទៅតាមឧត្តមគតិ តាមនិន្នាការនៃមនុស្ស ដែលជាអ្នកណែនាំ... ប៉ុន្តែនិយាយរួមទៅ យើងអាចឲ្យន័យអក្សរសាស្ត្របានដូចតទៅនេះ ៖

អក្សរសាស្ត្រគឺជាក្បួនខ្នាតឬជាវិជ្ជាមួយសិក្សាអំពីរបៀប និងវិធីបញ្ចេញសតិអារម្មណ៍ លាតត្រដាងមនោសញ្ចេតនា (បង្ហា

...ផុតគំនិតដោយសមត្ថភាពសិល្បៈ)  និងការត្រិះរិះរកមធ្យោ-បាយណាត្រូវនាំសំដែងនោះ ... ។ល។

អក្សរសាស្ត្រ មានសមត្ថភាព ផ្សាយបន្ទូរ មនោសញ្ចេតនា បណ្ដុះគំនិត បង្កើតការអប់រំឲ្យដល់មនុស្សនានាឲ្យស្គាល់គឺជួបជាកាព្យស្រ័យ . . ។ អក្សរសាស្ត្រមានទបតែសំអិតសំអាងនិងនិងជ្រើសរើសបណ្ដាវណ្ណកម្មពីអតីតកាល  ដែលជាស្នាដៃរបស់មនុស្ស ហើយលាបប្រេងផាត់ម្សៅតាមដំណើររឿងថ្មីនៃកាលៈទេសៈ  ដែលជាផលវិភាគនៃការជឿនលឿនរបស់មនុស្សជាតិផ្នែកសតិអារម្មណ៍និងស្មារតីក្នុងសម័យនិមួយៗដ៏ជាក់លាក់ ... ។ល។

អក្សរសាស្ត្រមានអាទិភូតសារបន្តបង្ហាញគតិរបស់សង្គមមនុស្ស  នូវកំរិតជឿនលឿន ឬ សភាពអន់ថយរបស់សង្គមមនុស្សក្នុងកាលៈទេសៈនិងក្នុងសម័យនិមួយៗ ។

អក្សរសាស្ត្រមិនមែនគ្រាន់តែជាសមាសភាពសម្ភារៈសម្រាប់

កត់ត្រាសំគាល់ទុកក្នុងក្បួនខ្នាត, ច្បាប់ទម្លាប់ ប្រពៃណី គម្ពីរ សាស្ត្រា រឿងព្រេងផ្សេងៗ ប៉ុណ្ណោះទេ ... សូម្បីតែបណ្ដារឿង ហេតុផ្សេងៗ ដែលមានតែនៅក្នុងពាក្យសំដីនិយាយតៗគ្នា ពី មាត់មួយទៅមាត់មួយនៃមហាជន យើងក៏គួរបានយកចិត្តទុក ដាក់ពិចារណាត្រិះរិះសំរិតតាមដានឲ្យណាស់ដែរ ពីព្រោះក្នុងពេល នៃរឿងទាំងនោះក៏មានសមត្ថភាពសួរទាញនឹងស៊ីជម្រៅទៅក្នុង សតិអារម្មណ៍មហាជនមិនតិចៗ រឿងនេះជាបញ្ហាសំខាន់ដែល គេត្រូវតែយកចិត្តទុកដាក់ ក្នុងពេលដែលគេសិក្សាពិចារណាការ ល្អគលាស់រីកចំរើន ឬការអន់ថយថែមយ៉ាងណាមួយរបស់ជាតិ នីមួយៗ ជាជាប់ៗ ក្រៅពីនេះ គេត្រូវសិក្សាឲ្យបានគ្រប់ផ្នែក ហើយយ៉ាងល្អិតល្អន់ទៀត ក្នុងវិស័យអក្សរសាស្ត្រ ដូចជាភាសិត. ទូរបញ្ចាក់ ល្ខោន របាំ ចរិយា ... ដែលជាកត្តានាំឲ្យយើង យល់បានច្បាស់ហើយត្រឹមត្រូវ នូវកិរិតវិវត្តន៍របស់គំនិតមនុស្ស ទូទៅទាំងស្រុងតាមទំនងសតិអារម្មណ៍ ព្រមទាំងការបកស្រាយ

ឆ្លុះបញ្ចាំងដូចជាផ្ទាំងសម្ភារៈរបស់សង្គមមនុស្សក្នុងជំនាន់នោះ ៗ

អក្សរសាស្ត្រមិនអាចមាន នៅដាច់ដោយឡែកតែម្នាក់ឯងបានទេ អក្សរសាស្ត្រមានការទាក់ទងជាប់ជំពាក់នឹងសង្គមមនុស្ស ជាក់ស្តែងគឺជាប់នឹងវិស័យការនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច សាសនា ... ។ល។ ដោយសារតែហេតុនេះហើយ បានជាអក្សរសាស្ត្រមានការល្អកល្អស់រីកចំរើនឬអន់ថយ ... ស្របទៅតាមសង្គមមនុស្សក្នុងកាលៈទេសៈនីមួយ ៗ ទៅតាមចំណេះដឹង គោលបំណងរបស់អ្នកដឹកនាំម្នាក់ៗ និយាយមួយបែបទៀតថា : អក្សរសាស្ត្រជាផ្លែផ្កានៃសង្គមមនុស្ស ។ អក្សរសាស្ត្រខុសពីវិទ្យាសាស្ត្រនឹងទស្សនវិជ្ជា តែត្រង់ប្រកាន់នូវវិស័យមុខជំនាញប៉ុណ្ណោះទេ ឯចំណែកគោលបំណងនៃអក្សរសាស្ត្រគឺដូចគ្នាតែមួយ ពីព្រោះវាអនុលោមដូចគ្នាទៅតាមនិន្នាការនៃអ្នកដឹកនាំ ។

# សមាសភាពដើម្បីលាតត្រដាងអក្សរសាស្ត្រ

និយាយរួមៗទៅគឺថាអក្សរសាស្ត្រមានសមាសភាព ៣ យ៉ាង ជាមូលដ្ឋានក្នុងការលាតត្រដាងនូវប៉ះពាល់សង្គមមនុស្ស ។

១– សំដីឬភាសា ជាមធ្យោបាយមួយដែលធ្វើឲ្យមនុស្សមាន ការកើតចិត្ត (មានអារម្មណ៍) បណ្តាលនាំឲ្យមនុស្សឲ្យមានផល ទាក់ទងគ្នា ។ ពិសេសគឺបះវូ្យន៍...បរោវាតវុតហ៊ុជាការុផ មួយដ៏សំខាន់ក្នុងការពណ៌នាបះបោរនៃរឿង ប្ញុះញ្ញាះញ្ញាំងបត អារម្មណ៍រំជួលរបស់តួមនុស្ស .. ។ល។

២– អក្សរជាមធ្យោបាយមួយយ៉ាងសំខាន់ ក្នុងការស្រាយ ក្នុងការស៊ើបស្រាវទៅក្នុងតំបន់ជិតឆ្ងាយ គ្រប់មជ្ឈដ្ឋាននានានិង ក្នុងកាលវេលា ក្នុងការសម័យនីមួយៗ អាចខ្ចប់ទុករាប់ សតវត្សក៏បានមិនរលុបបាត់បង់ ។

៣– កាយវិការ កាន់តែច្រើនត្រូវតែប្រើទៅលើវិការដើម្បី ទេវស្សនាមសភាវៈរួមយកក្នុងការបង្ហាញ អត្ថន័យ និងជួយ បន្ថែមឥទ្ធិពលសម្រស់ដល់សំដីនិយាយ ដើម្បីបណ្តាលចិត្តអ្នកមើលទៅ

មានការចាប់អារម្មណ៍ រំពឹង ទៅតាម បានកំពុងខ្ញុំនឹងទៅកាន់ទៅ

ក្នុងកាស្តើ ... ។

# វិធីអនុវត្តន៍

ត្រូវមានវិធីរូបបញ្ញាស្រាវជ្រាវធម្មជាតិ និងសិល្បៈនៃគ្រប់សម័យកាលយកមកដើម្បីដាស់ញ៉ើកការគិត ធ្វើឲ្យការគិតមានលក្ខណៈសកម្មភាព (ដាស់ញ៉ើកការគិត) និងមានទាក់ទាញ ... ។ ធ្វើឲ្យការគិតបានរីកចំរើនមានលក្ខណៈភាព និងរាជការនេះមិនបានប្រព័ន្ធ ដែលប្រមូលចម្រុះប្រភពប្រមូលមិនដឹងក្បាលកន្ទុយ បាតុភាពបាតុភាពនោះទេ ផ្ទុយទៅវិញយើងត្រូវតែជ្រើសរើសយកសម្ភាពណា និងបលខាណា ដែលជាមូលដ្ឋានមានបរិធូទៅ (a un caractère général) ម្យ៉ាងទៀតត្រូវដាក់ឲ្យមានជំពាក់ទៅនឹងសិល្បៈឲ្យកាន់តែស្មុគស្មាញ ដោយបន្ថែមបន្ថយ ឲ្យល្អ (d'une manière créatrice) ចៀសវាងនិតិនិយមគ្មានមេ (machinisme) ។ ដោយជ្រើសរើសកំណើ ជ្រើសរើសលក្ខណៈ

និងសកម្មភាពណាដែលមានបរិតផ្ទាត់ណាតិច្ចជាផ្នែករឿង ... ដែលបង្ហាញ ហើយសាយភាយមកណាតគ្រប់ផ្នែកព្យញ្ជនៈ ផង ប៉ុន្តែមិនត្រូវភ្លេចនូវលក្ខណៈពិសេសនៃឯកត្តជនម្នាក់ៗ ទេ ពីព្រោះលក្ខណៈពិសេសនេះ ក៏មានគុណភាពអាចនាំឲ្យវណ្ណកម្មអក្សរសាស្ត្រមានសោភណភាព និងមានតម្លៃក្នុងការគូសទាញសតិអារម្មណ៍មនុស្សខ្លាំងណាស់ដែរ ។

ត្រូវនាំគំនិតអ្នកអាន ឬ អ្នកមើលឲ្យយល់ពីខ្លឹមគ្រឿងគ្រប់វត្ថុបំណង និងនាំគេឲ្យទៅដល់ទិសដៅ ។

ប៉ុន្តែក្នុងការប្រើពាក្យ ប្រើកាយវិការ និងប្រើសំនួន ... ត្រូវឲ្យបេះមានការកំនត់ ទន់ភ្លន់ក្រៃលែងគំនិតបញ្ចេញបញ្ចូល អត្ថរស និងអារម្មណ៍ឲ្យស្របទៅតាមបញ្ញាស្រ័យ នៃកាលៈទេសៈ ដើម្បីបណ្ដាលនាំទោសរញ្ជួយចិត្តអ្នកមើល ឬ អ្នកអាន អ្នកស្ដាប់ ឲ្យមានការដើរស្របទៅតាមដំណើរនៃវណ្ណកម្មនោះៗ ... ។ល។

# ការបែងចែកប្រភេទនៃអក្សរសាស្ត្រ

និយាយដល់ការបែងចែកប្រភេទនៃអក្សរសាស្ត្រ យើងយល់ថាពុំមានការស្រួលស្រាញ់ប៉ុន្មានណាស់ មានពណ៌សម្បុរ មានរូបភាពច្រើនបែបផង ។

ក្នុងករណីដែលមានព្រឹត្តិការណ៍ចំឡែកៗ ជាប្រវត្តិសាស្ត្រលេចកើតឡើងជាការវិវត្តន៍ប្រែប្រួលម្ដងៗ អក្សរសាស្ត្រក៏ទទួលការប្រែប្រួលបែងចែកដោយត្រង់ៗ ហើយមានចរិតរើសអើង (Distinction) ដែកខ្វែងគ្នាសព្វគ្រប់ណាស់ទៅទៀតផង .. នេះយើងមិនទាន់និយាយដល់ការប្រឆាំងគ្នាខ្លះទៀតដែលលើសាកលលោក ដែលបានប្រែក្លាយទៅជាសមគ្គី និងនិតិពីឈ្មោះហៅគ្នាធំៗ សង្គ្រាមលោកលើកទីសង្គ្រាម បង្កការឈ្លានពានសាហាវខ្លាំងស្រស់ស្បើយ ។

ទោះបីរូបភាព ពណ៌សម្បុរអក្សរសាស្ត្រមានច្រើនបែបផែនផែន ប៉ុន្តែយើងអាចចែកញែកជាវណ្ណកម្មធំៗជាដាច់ដោយជាពីរផ្នែក គឺជា ២ វិស័យធំៗ មានដូចតទៅនេះ ៖

ក- វិស័យពាក្យសម្រាយ

ខ- វិស័យពាក្យកាព្យ និងចម្រៀង

ក- វិស័យពាក្យសម្រាយ បណ្ដាវណ្ណកម្មទាំងឡាយដែលនៅក្នុងវិស័យពាក្យសម្រាយធម្មតា យើងអាចចែងចែកបានជា២ផ្នែកទៀតបើតាមទស្សនៈយើងគឺ: ១- វណ្ណកម្មដែលមានចរិតជាទ្រឹស្ដី (Théorie) ២- វណ្ណកម្មដែលមានចរិតជាការពិពណ៌នា (Description) ។

១- ផ្នែកទ្រឹស្ដី រួមមានប្រភេទសិក្សាអប់រំឧបទេស (genre didactique) និងប្រភេទវោហារ (genre oratoire) ។

ប្រភេទសិក្សាអប់រំ(ឧបទេស)ប្រភេទនេះរួមមានបណ្ដាវណ្ណកម្មដែលមានចរិតបណ្ដុះបណ្ដាលការចេះដឹងដូចជាខាងវិទ្យាសាស្ត្រ តក្កសាស្ត្រ ចិត្តសាស្ត្រ ទស្សនវិជ្ជា បក្រាឡសាស្ត្រមានតាកសាស្ត្រជាដើម... ។ បណ្ដាវណ្ណកម្មដែលមានចរិតឆ្លើយឆ្លងគ្នា រវាងគ្នា (ចំនៀន) ខាងផ្នែកអក្សរសាស្ត្រ

ដោយមានគំនិតរបស់ពីរផ្នែកទៅលើវិធាន (loi) ដែលមានកន្ទួន មកហើយ ទីពីរពីរផ្នែកទៅលើយោបល់ឯកជនផ្ទាល់ខ្លួន...។ល។ ក្រៅអំពីនេះនៅមានបណ្តាប្រវត្តិអក្សរសាស្ត្រដែលជាមេរៀនពីអតីតកាលដុកឲ្យឃើញដកពីសោធនកម្មនិងបច្ចុប្បន្ន ដើម្បីជាគតិតទៅអនាគត នោះជាគុណវិបត្តិបុគ្គលសម្បត្តិដោយ ៗ (ដោយពីរផ្នែកទៅលើវណ្ណកម្ម ដែលមានលក្ខណៈរបស់តាមមធ្យោបាយសិល្បៈ) ។

## ប្រភេទថ្លែងការ Genre oratoire

១- ប្រភេទថ្លែងការរួមមានការថ្លែងកប់រៀបសេចក្តី ដែលមានចរិតឃោសនា ឬរបស់ក្នុងវិស័យនយោបាយដឹកនាំ ការថ្លែងក្នុងវិស័យតុលាការទីក្រុងក្រុមច្បាប់ឧទ្ទាប់ជាវិន័យផ្សេងៗ...។ ការថ្លែងប្រដៅ ហាសនា ការថ្លែងជូនកេសីចូហាចុការក្នុងពេលធ្វើពិធីចងសណ្ឋាគេចុ បុគ្គលដែលមានបុណ្យធានគ្មួយ ។

២– ផ្នែកកប់រៀបរួមមាន៖ បណ្តាអត្ថបទដែលមានចរិតជាប្រវត្តិសាស្ត្រ និងអត្ថបទដែលមានចរិតជាប្រលោម ។

## រឿងជាប្រវត្តិសាស្ត្រ (ខ្មែរ)

បណ្ដាអត្ថបទរឿងរ៉ាវនិទានទាំងឡាយ ដែលមានអត្ថរស សំខាន់ក្នុងការពិចារណាគិតរិះ មានការទាក់ទងផល់ព្រឹត្តិការណ៍ វិវត្តន៍ប្រែប្រួលនៃសង្គមមនុស្សពីយាយរូប មានការកេប៉ះរៀ ពីដំណើរវិវឌ្ឍនៃជីវភាពរបស់មនុស្សទាំងខាងស្មារតីផ្លូវ ខាងសង្គម និងលក្ខណៈសម្បត្តិលេះនៃសង្គមយុគ នោះគឺ ការតស៊ូដើម្បីពង្រីកសការៈថ្មី តស៊ូដើម្បីរំដោះ ពាល់ និងការតស៊ូដើម្បីរក្សាគុណធម៌ . . . ។

## រឿងជាប្រលោម (ខ្មែរ)

បណ្ដារឿងរ៉ាវទាំងឡាយ ដែលគេលាតត្រដាងឡើង ដោយមានបរិកថាខ្លះៗ ខ្លីខ្លួនល្អ មានការស្រមើស្រមៃ មាន លក្ខណៈធ្វើឲ្យអ្នកអានឬអ្នកស្ដាប់រវើរវាយ, ស្រនេះស្រណោច អន្ទ្រាគអណ្ដែន មានការបាច់ការម្នាក់ ការរំភើបចិត្ត (បណ្ដាល បានខ្ញុំមនោសញ្ចេតនាអ្នកស្ដាប់) ហើយការពណ៌នានាំអ្នកអាននិង

អ្នកស្ដាប់ឮទៅដល់ទីបំផុតដែរ ជាវត្ថុចំណេះការចាក់ចិត្តនៃខ្សែរឿង ទោះជាធាតុក្ដី ដែលជាទស្សនៈយ៉ាងពិតប្រាកដរបស់អ្នកនិពន្ធទៀតផង (ទោះជាជីវទស្សនក្ដី (Conception de la vie) ឬក៏ចក្រវាឡទស្សនក្ដី (Conception du monde) ។ និយាយមួយបែបទៀតថា : រឿងប្រលោមគឺជារឿងប្រឌិតឬរឿងនិទានមួយយ៉ាងមានលក្ខណៈទូទៅ ក្នុងនោះរឿងមានការផ្សងព្រេងដោយរបៀបរៀប ដែលតាក់តែងឡើងដោយគំនិតរបស់អ្នកនិពន្ធ ។ បន្ថែមទៀត ក្នុងន័យនៃផ្លូវរឿងប្រលោមច្រើនតែមានលក្ខណៈជានិមិត្តនៃកាលៈទេសៈ ពេលវេលា ឬ សម័យនីមួយៗ ដែលអ្នកនិពន្ធមានការចាប់អារម្មណ៍ទោះជាខាងការឈឺចាប់, ការកោតសរសើរ ឬ ការអបអរ និងការផ្ដន្ទាក៏ដោយ ... ។ល។

ប្រលោមលោកមានន័យ និងរូបភាពច្រើនសន្ធឹកសន្ធាប់ណាស់ អនុលោមទៅតាមជំនាន់ តាមទស្សនៈនិងតាមលក្ខណៈជីវភាពរបស់អ្នកនិពន្ធដូចជា : រឿងប្រលោមមានចរិតជាប្រវត្តិ

សាស្ត្រ ប្រលោមលោកមានចរិតជាចំហាព្រះសាសនា... ប្រលោមលោកកាលក្រោយត្រូវជាដើមហេតុច្រើន បញ្ហាសង្គមមនុស្ស មានការរិះគន់ទំនៀមទំលាប់ មានប្រលោមលោកខ្លះនិយាយតែពីសេចក្តីស្នេហា (កាមគុណតណ្ហា) ៈ មួយមុខប៉ុណ្ណោះ...។

## រឿងព្រេង (ទូទៅ) Légende

បណ្តុំនូវរឿងពីកំណាត់ដើម ដែលនិយាយកប់រឿងតែពីវត្ថុស្រួតពេហាកទេគរ... ជាដើម មានចរិតអស្ចារ្យហួសសម័យ រឿងក៏ជាគំនិតទិដ្ឋិមនុស្សបុរាណ (គំនិតយល់ស្រមៃ-Utopisme) ៈហើយពិពណ៌នារៀប ក៏មិនសូវឃើញមានប្រើពាក្យសំដីពេរោះឲ្យក្បោះក្បាយពន់...។ មានរឿងព្រេងមួយពួកទៀតមានចរិតបែបប្រជាប្រិយ (populaire) ដែលគេហៅថារឿងព្រេងប្រជាប្រិយ រឿងនេះភាគច្រើនគឺជារឿងអនាមិក (រឿងដែលគ្មានឈ្មោះអ្នកនិពន្ធ) រកឈ្មោះអ្នកដាក់ពេញមិនឃើញ ។

តាំងពីដើមមកគេប្រើនិយាយឲ្យគ្នាស្តាប់ៗ គ្នាពីមនុស្សគ្រប់

ទៅមនុស្សម្នាក់ រឿងអស់ទាំងនោះ មានគុណភាពជាក់ស្ដែងក្នុង ការដឹកនាំមនុស្ស ចលនាមនុស្សសម្បើមណាស់ដែរ ឲ្យមនុស្ស ទៅកាន់សភាពសកម្មនិងគន់ផល់សក្ការៈដែលបានផលគួរគាប់ ក្នុងសម័យនោះគេយល់ថាជាមិនសមរម្យ ... ។ល។

## រឿងប្រឌិត (និទាន) Conte

រឿងប្រឌិតមានលក្ខណៈប្រែប្រួលទៅតាមប្រភេទ ដូចជា រឿងប្រឌិតមានចរិតជាទស្សនវិជ្ជា ជាច្បាប់ប្រៀនប្រដៅ កំដូង ចំកាសដើម្បីសប្បាយ ... រឿងព្រេងជាតិនិគតិយមរើករាយ អណ្ដែតអណ្ដូងគួរឲ្យស្រណោះស្រណោចគួរឲ្យភ្ញាក់ផ្អើល ។ល។ មាន រឿងប្រឌិតខ្លះទៀតមានលក្ខណៈស្លូតត្រង់ ស្រគត់ស្រគំណែនាំ ឲ្យមនុស្សមានសភាពបសាទនឹងធឹង ... ។

## រឿងល្បើក (រូបក) Fable

រឿងល្បើកគឺជារឿងដែលគេលើក គេប្រឌិតឡើងដោយ ការចាប់ការណ៍នៃអ្នកនិពន្ធ ដើម្បីរិះគន់ទំនៀម ដើម្បីសរសើរ

លើកតម្កើង ដើម្បីបញ្ចេញគុណសម្បត្តិសារៈមួយប្រការដោយ បរិកថាថ្លៃថ្នូរ...។ ក្នុងការតែងសេចក្ដីខ្លះ គាត់ច្រើនតែ លើកពាក្យគួរក្នុងរឿង [illegible] ពាក្យណាខ្លះច្រើនយកតែ [illegible] យក ក្រជាក់ [illegible] បង្ហាញ [illegible] រូបភាពពិសេសរបស់ កវី ជាកាព្យ ឬ ជាបទមានពាក្យ ៣, ៦, ៨ ... ។ល។

## រឿងជាតក (ពិសេសចំពោះអក្សរសាស្ត្រខ្មែរ)

ជាតកនេះ ជារឿងដែលនិយាយអំពីការកសាង បារមីរបស់ព្រះពុទ្ធ ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធ អនាគត ។ នេះបើនិយាយតាមពុទ្ធនិយម ។ រឿងទាំងនោះ ស្ទើរតែទាំងអស់ប្រែចេញមកអំពីគម្ពីរបាលី មានគម្ពីរបញ្ញាស-ជាតក ជាដើម ។ បើនិយាយអំពីព្រហ្មញ្ញនិយមវិញ គឺជារឿង ការដែលមានទាក់ទងដល់ព្រះជាម្ចាស់ទាំង ៣ អង្គ គឺព្រះព្រហ្ម ព្រះនារាយណ៍ ព្រះឥសូរ រឿងនិយាយដល់ព្រះនារាយណ៍ ចុះអវតារ (នារាយណ៍អវតារ ១០ ជាតិ) ពោលរឿងមហាភារត-

យុទ្ធ រឿងកាមភក្តិជាដើម ។ល។ ជារឿងលាតត្រដាងឡើងនូវ សភាវៈ មួយមកបង្ហាញបង្ហាលសភាវៈភាគគ្រប់គ្នា គោលគំនិតការពារ វប្បធម៌ក្នុងផនការ (ទៅ:ឬខេសត់ណ្ឌៀ) ការពារទឹកដី..បង ឲ្យកា-ទ្រព្យហ្វ៍ទាន់ដើម . . . ។ល។

## រឿងដំណឹង (ថ្មី) Nouvelle

បណ្ដារឿងកំរដែលមានចរិតជាដំណឹង ការពេចរៀបប្រកប ដោយពាក្យពេចន៍ម៉ឺនម៉ាត់ហ្មត់ចត់ច្បាស់លាស់នឹងមានលក្ខណៈ ប្រាប់ជាដំណឹង ។

« បណ្ដារឿងកំរ ភាំងពីស់ដែលបានអធិប្បាយ ខាងលើ គេអាច សរសេរជារបៀបល្ខោន ជាកំណាព្យហើយ ឬ ជារបៀបប្រលោម លោក . . . ស្រេចលើការប៉ុនប្រសប់ និងការឈ្លាសវៃរបស់អ្នក និពន្ធបំណោះ ក្នុងការរចនាតែងផ្ការឿងនិមួយៗ ដោយតាម រូបភាពណាមួយ » ។

# ១– វិស័យពាក្យកាព្យ

អក្សរសាស្ត្រក្នុងវិស័យពាក្យកាព្យ ត្រូវមានសាស្ត្រច្បាប់ និងសាស្ត្រល្បើកនានា បទចម្រៀងវែងខ្លីដែលលាតត្រដាងឡើង នៅគំនិតស្នេហាស្មោះត្រង់បំរាមរះខៀមខ្ជាប់ប្រពៃណី បទចម្រៀង វែកញែកសាទរសេចក្ដីទេខ្ទាប់ពីបាបខ្វល់ឥយដំនឿមួយ ៗ

## បទចម្រៀងស្នេហា

តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាល បទចម្រៀង ឬ កំណាព្យដែលបានបង្ហាញឡើងនូវមនោសញ្ចេតនាស្នេហាក៏មាន សន្ធឹកសន្ធាប់ណាស់ដែរ ។

បើយើងប្រៀបធៀបរវាងសម័យតាំងពីនេះទៅ យើងអាច យល់ថា :

ក– អតីតកាល = កំណាព្យ ឬ បទចម្រៀងខាងផ្នែក ស្នេហារវាងប្រុសស្រី (ប្រុស + ស្រី) ភាគច្រើនមានលាយឡំ បម្រុះនៅក្នុងការអារកសាកម្មរបស់ខ្លួន ហើយមានចរិតបាត់ផ្លាក់

ទៅតាមទំនៀមទម្លាប់និយមថែមទៀតទេ គមន៍ ប៉ុន្តែបើយើង ពិចារណាឲ្យជ្រៅជ្រះ យើងឃើញថា សុភាពស្នេហាជំនាន់នោះ មានចរិតស្លូតបូតស្មោះត្រង់ខ្លះតាមបែបបុរាណ មានចរិតសន្តក សន្តិឧបត្ថម្ភខ្លះពីសំណាក់គ្រួសារ ... ។

១– បច្ចុប្បន្នកាល = សព្វថ្ងៃនេះ គេនៅប្រើចម្រៀង នឹងកំណាព្យបែបស្នេហាកាលបង្កើនពីអ្នកចម្រៀង (មិនសូវ មានចរិតទំនៀមទម្លាប់ឲ្យហួសហេតុពេកទេ ប៉ុន្តែមានអត្ថន័យខ្លះ បំរើតែការស្នេហាមួយមុខប៉ុណ្ណោះ) ។ ចម្រៀងតាំងកំណាព្យ ១ ពួកបំរើការស្នេហាដែរ ប៉ុន្តែមានចរិតកសាងខ្លះ ១ ពួកទៀតបំរើ តែសេចក្តីស្នេហាមួយមុខប៉ុណ្ណោះ យើងអាចហៅថា "ស្នេហា ដើម្បីតែស្នេហា" ខុសគ្នានឹងស្នេហាដើម្បីកសាងស្ថាបនា ... ។

## ចម្រៀងអប់រំ

កំណាព្យផ្សេងៗ ដូចជា «ស្រីពុកស្រូវ» «កូនអើយកើត មេបា ចូរក្សាទៀនចុកទៅ ...» អប់រំខាងវិស័យសេដ្ឋកិច្ចរបស់

យើងជំនាន់ដើម ចម្រៀងផ្សេងៗទៀតដែលមានចរិតប្រជា-មានិតខ្លះ ដូចជាបទកំពោកូន បទចម្រៀងសន្យាគ្នាប្រុសស្រី... សាស្ត្រា, ច្បាប់ផ្សេងៗ... ភាគច្រើនមានចរិតអប់រំមនុស្សឲ្យមានចរិយាសម្បត្តិមួយយ៉ាង ខ្លួនតាមទស្សន៍សាសនា ឬទំនៀមទម្លាប់ខាងពិធី[illegible] ឬពិធីផ្ដាប់ផ្គួនគ្នារវាងមនុស្ស ហើយមានការរើសអើងខ្លះៗដែរ ...។ មានកំណាព្យខ្លះទៀតជាពាក្យកាសិត ឬពាក្យចាស់ មានគតិសំខាន់ៗ ដែលលាតត្រដាងឡើងនូវគុណសម្បត្តិ និងគុណវិបត្តិនៃសង្គមជំនាន់នោះ (ដូចជាពាក្យថា ផ្ទះរៀបកុំបេះបង់ ផ្ទះណាត្រង់កុំដើរហោង...) ។

បណ្ដាកំណាព្យ ឬ ចម្រៀងក្នុងអក្សរសាស្ត្រខ្មែរយើងជំ-នាន់នោះ ក៏មានចរិតអប់រំផ្លូវសង្គមរដ្ឋ, ចរិយា, សេដ្ឋកិច្ច, សាសនា មុខជំនាញ...ពិធីផ្សេងៗ មានការរិះគន់ទំនៀមនេះទម្លាប់នោះ ឬ ក៏កែច្នៃកំហុសក្នុងគោលគំនិតកែប្រែចរិយា (ដូចជាកំណាព្យរៀបអំពីកាយវិការនៃអ្នកប្រមឹក) ។

# វីរកម្មនិទាន ÉPOPÉE

បណ្ដាចម្រៀង ឬ កំណាព្យដែលថ្លែងឡើងបន្ទាប់ អំពីជោគជ័យជំនះក្នុងវិស័យអ្វីមួយ ដូចជាពីដើមគេច្រៀងសរសើរទេព្តាក្នុងពេលធ្វើស្រែចំការ បច្ចុប្បន្ននេះមានចម្រៀងអនុស្សាវរីយ៍រំឭកទិវាផលជ័យជំនះ បុណ្យឈ្នះឬការស្លាប់នាអ្វីមួយ ។

# បណ្ដាញឫសគល់អក្សរសាស្ត្រនៃជាតិនីមួយៗ

ទោះនៅក្នុងយុគណាក៏ដោយ ពាក្យថា "ជំនាន់, សម័យ ឬ កាលៈទេសៈ" ក៏មានន័យនឹងកត្តសេចក្ដីទូលំទូលាយណាស់ ហើយចាំបាច់តទៅ មានអាការៈប្រួលប្រែបណ្ដាលមកពីគំនិតទាំងអស់របស់សង្គមមនុស្សនៅក្នុងពេលនីមួយៗ ថែមទៅទៀតផង ។

ឧទាហរណ៍ដូចជាពាក្យថា "ជំនឿ" ។ ពាក្យថា "ជំនឿ" មួយនេះ យើងនឹងបរិយាយឲ្យទូលាយដូចតទៅនេះថា ៖

មនុស្សយើងជាធម្មតាគេតែងតែមានជំនឿ, ជំនឿដែលគេជឿនោះ មានចរិតស្របទៅតាមសមត្ថភាពរបស់អ្នកដែលគេជឿ ហើយវត្ថុដែលគេជឿនោះទៀត ក៏ស្របទៅតាមពេលវេលា (ស្របទៅតាមកាលៈទេសៈថែមទៅទៀតផង ។ ជាសេចក្ដីថា : ក្នុងករណីដែលមានវត្ថុ ឬ សភាវៈអ្វីមួយ ជាមាន (Exister) កើតឡើង មនុស្សគេជឿថា វត្ថុនោះ សភាវៈនោះជាមានមែនដោយវិចារណញ្ញាណតាមហេតុផល មនុស្សមិនគ្រាន់តែជឿតាមសភាវៈឬវត្ថុអ្វីមួយដែល

មានកន្លងមកហើយនោះទេ សូម្បីតែសង្គមណាដែលនឹងមាននៅក្នុងអនាគត ក៏មនុស្សគេអាចជឿជាក់បានដែរ ពីព្រោះមនុស្សគ្រប់សង្គមមួយ មានការត្រិះរិះពិចារណារកហេតុផល, មនុស្សមានខួរក្បាលចេះគេចឲ្យឆ្ងាយទប់ទល់នឹងធម្មជាតិ ព្រមទាំងដោះស្រាយធម្មជាតិនិយាយរួម . . . ។

យើងគប្បីពិនិត្យមើលក្នុងវិស័យអក្សរសាស្ត្រ ដើម្បីជាជំនួយដល់ការពិចារណាត្រិះរិះស៊ីជម្រៅឲ្យយល់ច្បាស់នូវមនោសញ្ចេ-តនានិងទន់ទ្រាយគញ្ញាស្រ័យរបស់មនុស្សក្នុងមួយជំនាន់ៗ ។

ហេតុអ្វីបានជាអក្សរសាស្ត្រក្នុងជំនាន់ដំបូងនៃមនុស្សនៅគ្រប់ប្រទេស ពុំមានចរិតរវើរវាយ និងមានគន្លងការគិតនិយម ? (យល់សច្ចនិយម) ។

យើងអាចឆ្លើយដោយលក្ខណៈទូទៅឲ្យទូលាយថា ៖ នេះហើយដែលគេហៅថាសម័យ ឬ កាលៈទេសៈ ឬជំនាន់របស់សង្គមមនុស្ស ! ។ មនុស្សមិនអាចផ្តាច់បានទេ បើមនុស្សមិនទាន់ចម្រើន

ទម្លាប់ . . . ពី ២ ពី ៣ ឬ ៤ ៤ គួរនេះ ដើម្បីទោលការលើយ គ្មានលើកទី ១ . . . ។ ប៉ុន្តែបញ្ហាសិក្សានេះនៅត្រង់ថា ៖ បើមនុស្សធ្វើការអ្វីមួយខុសក៏មិនទាន់គ្រោះថ្នាក់ប៉ុន្មានទេ គ្រោះថ្នាក់ខ្លាំងនៃត្រង់មនុស្សដឹងខ្លួនថា ខុសហើយនៅតែមិនព្រមកែ គឺថាបើយើងចេះគេឃើញការខុសហើយ មនុស្សគប្បីយកការខុសនោះមកសិក្សាដើម្បីរកការត្រូវ បើមនុស្សធ្វើបានត្រូវហើយគប្បីយកការត្រូវនោះមកសិក្សា ដើម្បីពង្រីកការត្រូវនោះឲ្យកាន់តែទូលាយហើយ បន្ថែមទៅទៀត . . . ។ល។

យើងសូមជូនឫសគល់នៃអក្សរសាស្ត្ររបស់ប្រទេសខ្មែរ ។ ដើម្បីធ្វើជាមូលដ្ឋាន ក្នុងការសិក្សាប្រៀបធៀបរបស់អស់លោកអ្នកអាន . . . ។

## ប្រទេសចិនប្រជាមានិត

កាលពីជំនាន់សតវត្សរ៍ទី ៦ ទៅដល់សតវត្សរ៍ទី ១២ មុនគ្រិស្តសករាជ ទៀនអក្សរសាស្ត្ររបស់ប្រជាជនចិនគេមានគម្ពីរ

(ឆ្ង-គីញ) ហៅថា គីញ-ប៉ិ សរសេរជាពាក្យកាព្យ ចំរៀង របស់ប្រជាជនគ្រប់ជនបទ សម្រាប់ច្រៀងឆ្លើយឆ្លងគ្នាពីរនាក់ៗ មួយទៅរកនាក់មួយ ... ។

គម្ពីរនេះរួមមានជាង ៣.០០០ អត្ថបទនិយាយរាប់រៀបអំពី-ធៈនាសសេក្ដីស្នេហស្នូកបួតរបស់ប្រជាកសិករនៅជនបទ លោកគ្រូ-ជានះឡើងនូវការឈឺចាប់ គាត់ប្រកបចេញរបស់មនុស្សក្នុងជំនាន់នោះ បណ្ដាញការស្រះចេញបត្ដ, ការទ្រាប, ការក្ដៅក្រហាយ, សប្បាយរីករាយ ... ជាពិសេសក្នុងគម្ពីរនេះមានអត្ថបទនិយាយសរសើរលើកតម្កើងព្រះមហាក្សត្រ ក្នុងការបន, សនសុំពរសេក្ដ-សក្ការ ... ។

នៅក្នុងសម័យ ខុង-ជឺ Confucius លោកនេះបានពិនិត្យ ត្រិះរិះមើលក្នុងចំណោមអត្ថបទទាំងឡាយនៅក្នុងគម្ពីរ ឆ្ង-គីញ លោក ខុង-ជឺ បានជ្រើសរើសយកប្រហែលជា ៣០០ អត្ថបទប៉ុណ្ណោះ ហើយលោកបានបញ្ចូលថែមទ្រឹស្ដីទាំងឡាយផ្សេ

មានគេគួរសមតែមនុស្សជំនាន់នោះ ឲ្យមានគំនិតខំរកបញ្ញាស្រួល ស្របទៅតាមគំនិតរបស់លោក ។

ក្នុងការប្រៀបធៀប អក្សរសាស្ត្រចិនក្នុងជំនាន់ ខុង-ជឺ មានការលូតលាស់ជឿនលឿនខ្លះដែរខាងផ្នែកគំនិតសម្ភារៈនិយម ប៉ុន្តែចរិតពិសេសរបស់ ខុង-ជឺ គឺឆ្ពោះទៅខាងបរលោកខ្លាំងពេក (ស៊ើ តើ, សាន, ធុង) មានវណ្ណកម្មផ្សេងៗ មានស្នាដៃបំពាក់មនុស្សឲ្យឧបត្ថម្ភវណ្ណៈខ្លាំងពូកែ លើកតម្កើងទំនៀមទម្លាប់ដែលគ្មានហេតុផល ... ដូចជាស៊ីបាយកុំឲ្យរសាត់ពីចាន, ដួសបាយកុំចាក់ដល់គល់ចាន ... គ្មានសមភាពប្រុសស្រី ដូចជាបេបពានសែ (សែគួច, សែល្អ, សែរលើ ... យកឈ្មោះតាមសែប្រុស) ស្រីគ្មានកម្ម មានវិធីដូចជាស្ត្រីកាលពីដើមដែរ ... តទ្បូវនេះគេហៅថាសែគក្រាលទឹក ... ។ល។ ការសនារបស់មនុស្សរស់នៅក្នុងសង្គមត្រូវផ្ញើទៅលើព្រះម្ចាស់សួគ៌ ។

ជល់មកសព្វថ្ងៃនេះ ប្រជាជនចិនបានទ្រាំទ្រានរឿងអក្សរ

សាស្ត្ររបស់ជាតិគេឲ្យមានតម្លៃជាអតិបរមា ស្របទៅតាមផលប្រយោជន៍នៃសេចក្តីត្រូវការរបស់ជីវិតខាងផ្នែកសម្ភារៈ គឺដូចជាខាងស្ថាប័នប្រកបដោយលក្ខណៈ វិទ្យាសាស្ត្រ ហើយសកម្ម... ព្រោះបើពោលតាមគតិប្រើន (ជាមូលដ្ឋាន) ទូទៅផ្នត់គំនិតដែលមានជំនឿមិនសមហេតុផលនិងជំនឿមិនច្បាស់ ដែលនាំទៅរកយល់សប្តិនិយម គ្មានហេតុគ្មានផល វៃលជាមួយសត្វចល់ជីវកាតបមាន . . . ។

## ប្រទេសខ្មែរយើង

ទៀតអក្សរសាស្ត្ររបស់ខ្មែរយើង តាំងពីបុរាណមក និយាយរួម គឺមានលក្ខណៈគំនិតនិយមជាមូលដ្ឋានដែលបែកចេញមកពីឥទ្ធិពលនៃអក្សរសាស្ត្ររបស់ជនជាតិឥណ្ឌា ។

ឥទ្ធិពលនៃបណ្តាអក្សរសាស្ត្ររបស់ឥណ្ឌា បានចូលមកក្រោមប្រទេសខ្មែរ ក្រោយការផ្សាយសាសនារបស់គេដែលមានបរិតតិយោធិ៍ខុសគ្នា ប៉ុន្តែមានមូលដ្ឋានគំនិតនិយមដូចគ្នា ។

១– អក្សរសាស្ត្រដែលជះចេញមកពីមជ្ឈ៖

ឋានព្រហ្មនិយម បណ្ដារឿងក៏ដែលបកប្រែ ដកស្រង់ ឬ និយាយត្រួតទៅថា: បណ្ដារឿងក៏ណាដែលមានទាក់ទងដល់គម្ពីរវេទទាក់ទងដល់ការសរសើរលើកតម្កើង ព្រះអាទិទេព ព្រះម្ចាស់សួគ៌មានព្រះត្រីមូរតិ គឺព្រះនារាយណ៍ ព្រះព្រហ្ម ព្រះឥសូរ

ភាគទីពីរដល់ការបន់ស្រន់កោតក្រែងកោតខ្លាចព្រះយេណ៍ មានរូបជាទៀនធូប ស្លាបត្រួរ... យកបុប្ផាខ្ទុំតាំងបូជា ព្រះយោះឆ្នុកយជំពណ៌ពីទេ... ព្រោះតាកនតិបណ្ឌិត និងសុភទិព្វយដែលជាទស្សនតិរបស់លោក ដូចជារឿងរាមកេរ្តិ៍ វិបុសភ្នំ មហាភារតយុទ្ធ... ជាដើម ។ រឿងអស់ទាំងនេះ គឺជាវណ្ណគតិនៃព្រហ្មនិយម មានចរិតយល់សុភ័, មិនជាក់ស្តែង, តែសម្អិទ្ធិមានគុណភាព ការពារផលប្រយោជន៍ ក្តុកព្យួននៃជាតិឥណ្ឌា ។ល។ អក្សរសាស្ត្រនេះបានហូរចូលមកប្រទេសខ្មែរយើងតាំងពីមុនសម័យអង្គរម្ល៉េះ គឺថាតាំងពីគម្ពុជសតវត្សរ៍ទី ១ ទី ២ ... ។

២– អក្សរសាស្ត្រដែលផុសចេញមកពីមជ្ឈ-ដ្ឋានពុទ្ធនិយម បន្ទាប់ពីព្រហ្មញ្ញនិយមមក មានចលនាអក្សរ-សាស្ត្រមួយបែបទៀត មានការប្រសើរជាងមុនច្រើន មានលក្ខណៈណែនាំមនុស្សឱ្យទៅកាន់សេចក្តីសុខ មានបាកសេគម្ពុ-ខ្ទះ ប៉ុន្តែមានមូលដ្ឋានគំនិតនិយមដូចគ្នា គឺបណ្ដាអក្សរសាស្ត្រដែលមានទិដ្ឋភាពពុទ្ធនិយម ចេញមកពីស្រុកផ្សេងៗដូចគ្នា ប៉ុន្តែបែកជាពីរពួក គឺពួកគណៈមហាយានមួយ និងគណៈហិន-យានមួយ . . . ។

គន្ថិស័យពុទ្ធនិយមនេះឃើញមានវណ្ណកម្មជាច្រើនដែលមានការពាក់ព័ន្ធដល់គម្ពីរបាលី រឿងដែលដកស្រង់ ឬ បកប្រែចេញមកពីគម្ពីរព្រះត្រៃបិដកនិងបញ្ញាសជាតកជាដើម... និយាយអំពីការកសាងបារមីរបស់ពោធិសត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធគង់អនាគត និងមានទិដ្ឋភាពធ្ងន់ទៅខាងបរិយាយប្រដៅមនុស្សឱ្យបានត្រឹមត្រូវ បាត់ផុតទៅតាមសាសនាឃ្លាតពីផ្លូវលោកខ្ទះៗ . . . ។

សាសនា ខុង-ជឺ (៥៥១ - ៤៧៩ មុន គ.ស.) ប្រដៅមនុស្សឲ្យផ្ចង់ទៅខាងឥហលោកនេះ ប៉ុន្តែគាត់មិនសូវបានប្រើកប្រៀនចំពោះបុណ្យបាប ក្នុងការកាប់សម្លាប់សត្វធាតុយកមកជាម្ហូបតែតែឯង មានសេចក្តីថា : ខុង-ជឺ ប្រដៅមនុស្សឲ្យមានគោលគំនិតរបៀបព្រះពុទ្ធដែរខាងឥហលោកធម៌ ប៉ុន្តែមានលាយឲ្យចរិតសេដ្ឋកិច្ចកំនួញ (សម្ភារៈនិយមខ្លះ) ក្នុងការរកស៊ីបរិភោគកល់ខ្លួន ... ។ល។

ក្រៅអំពីចលនាអក្សរសាស្ត្រដែលមានឥទ្ធិពលក្នុងការវិវត្តន៍តាមគោលគំនិតពីខាងលើ ខ្មែរយើងនៅមានចលនាអក្សរសាស្ត្រពីរបែបទៀតដែលមានឥទ្ធិពលជាជាតិនិយមមួយ និងជាប្រទេសនិយមមួយ ដែលកើតឡើងអំពីវប្បធម៌របស់ជាតិដទៃដែលគេផ្សាយចូលមក ។

អក្សរសាស្ត្រដែលមានឥទ្ធិពលជាជាតិនិយម (ខេមរនិយម) និយាយមួយទៅគឺបានលាតត្រដាងឡើងនូវព្រឹត្តិការណ៍

ខ្ញុំថែរក្សាជីវិតរបស់ជាតិយើងពិតមែនហើយ ប៉ុន្តែបើយើងពិនិត្យឲ្យល្អិតល្អន់ទៅ យើងនឹងឃើញថាមានចរិតតូចនិយមនិងព្រហ្មនិយមខ្លះៗ លាយឡំគ្នានៅក្នុងនោះ ... ។ល។ ការនេះជាធម្មតាពីព្រោះថាការប្រើនៅខ្មែរយើងមានឥទ្ធិពលនៃពួកអក្សរសាស្ត្រដែលតូចនិយមនិងព្រហ្មនិយមនេះ សម្លឹងសម្លាប់នៅក្នុងគំនិតនៅហើយៗ បុគ្គលផ្សេងទៀតផង ។

ក្នុងសម័យប្រទេសយើងត្រូវពួកអាណានិគមនិយមជិះជាន់ វប្បធម៌សេរីភាពនិយមរបស់ពួកមានសន្ទុះខ្លាំង ក៏នាំឲ្យអក្សរសាស្ត្ររបស់ខ្មែរយើងមួយផ្នែក មាននិន្នាការទៅតាមពួកគេទៅ ដែលយើងឲ្យឈ្មោះថា : អក្សរសាស្ត្រផ្គាប់បរទេសនិយម ។ ពាក្យថាបរទេសនិយមនេះ គឺមានន័យថាបរទេសដែលមានឥទ្ធិពលច្រើនជាងគេ គឺព្រោះថា បរទេសដែលនៅជិតខាងយើងដូចជា សៀម, យួន, ចិន, លាវ ... ។ល។ ក៏ត្រូវទទួលឥទ្ធិពលនៃវប្បធម៌បរទេសបស្ចិមនិយមដូចយើងដែរ ។

និយាយសង្ខេបទៅថា: អក្សរសាស្ត្រខ្មែរយើងមានចិន្តា ៤ បែប ឬថាការចលនានៃអក្សរសាស្ត្រខ្មែរយើងបានទទួលឥទ្ធិពល ៤ យ៉ាង ដែលជាចិន្តាការប្រែក្រួតទៅតាមកាលៈទេសៈនិមួយៗ ៗ

ក្នុងសម័យនេះ នគរយើងបានឯករាជ្យ ទៀតអក្សរសាស្ត្ររបស់ជាតិយើងមានសន្ទុះយ៉ាងច្រើន ដោយប្រៀបធៀបពីអតីតកាល ៗ បណ្ដាវណ្ណកម្មយ៉ាងសន្ធឹកបានផុសឡើងបន្តបន្ទាប់គ្នា មានចរិតចម្រុះ (mixte) កាន់លក្ខណៈនយោបាយ, សេដ្ឋកិច្ច, វប្បធម៌, សង្គមកិច្ច . . . (លោកិយសច្ចៈ) ប្រតាញប្រទង់មនុស្ស ណែនាំមនុស្សឲ្យទៅតាមចិន្តាការនៃអ្នកសរសេរ ប៉ុន្តែទោះបីយ៉ាងណា និយាយរួមទៅទៀតអក្សរសាស្ត្ររបស់ខ្មែរយើងក្នុងសម័យនេះក៏មានចរិតជាក់ស្ដែង, មានលក្ខណៈវិទ្យាសាស្ត្រច្រើនក្នុងការបំរើសង្គមមនុស្សតាមលោកិយសច្ចៈ . . . ៗលៗ គឺជាអក្សរសាស្ត្រដែលចាប់ផ្ដើមមានមូលដ្ឋានជាសម្ភារៈនិយមហើយ ៗ

# ប្រទេសឥណ្ឌា

តាំងពីដើមមក ប្រទេសឥណ្ឌាមានរឿងអក្សរសាស្ត្រ ផ្នែកខាងគំនិតនិយមមិនអន់ណាស់ដែរ ពិសេសគឺប្រទេស ឥណ្ឌានេះហើយដែលជាអ្នកផ្សាយឥទ្ធិពល នៃវប្បធម៌គំនិត និយមចំពោះភូមិភាគនេះ ដោយនិយាយរួមទៅ ។

ឥណ្ឌាគេចូលចិត្តកាន់តាមទំនៀមទៅតាមលទ្ធិ ដែលមាន ព្រះត្រៃមូរតិ គឺព្រះព្រហ្ម, ព្រះវិស្ណុនិងព្រះស៊ីវៈជាគំណាន ប៉ុន្តែ មនុស្សដែលចូលចិត្តគាត់ច្រើន (ភើយកមធ្យម) គឺគណៈ ព្រះវិស្ណុ (ព្រះនារាយណ៍ ឬ ហៅថាព្រះរ៉ាម) ។

រឿងរ៉ាវជាអក្សរសាស្ត្រក្នុងវិស័យការខ្មែរនេះ ច្រើនតែចុះ ចេញមកពីគម្ពីរវេទ ។ វេទប្រហែលជាបួនជើង ។ អត្ថបទនៅ ក្នុងគម្ពីរវេទនេះមានគត់សំគាល់នូវពាក្យស្រីជាធម៌តាពិសម្រាប់ សូត្ររបស់ប្រជាជនគេ) (មានអ្នកប្រាជ្ញសាស្ត្រខ្លះបាននិយាយ ថា: គម្ពីរឈ្មោះវេទនេះ ជាឈ្មោះលទ្ធិមួយខាងមុខលទ្ធិព្រហ្ម

ចាប់កំណើតដំបូងបង្អស់នៅស្រុកអេហ្ស៊ីប ដែលនិយមការបូជា យកៈទត្តាត្រាចព្រាហ្មណ៍ សាក្យអ្នកតាជាធំ ... មិនមែនយកព្រះត្រៃបុគ្គជាធំទេ) ។

គម្ពីរវេទមាន ៤ ក្បាលធំ ។ ប៉ុន្តែអោយក្បាលទី ៤ មានក្រោយគេ ហើយគេហៅតែមុនមកតែបី ម្ល៉ោះហើយគេច្រើនហៅថាវេទត្រ័យ (ត្រៃវេទ) ។

គម្ពីរវេទ ឬ ហៅថា សាសនាវេទនេះ គឺជាសាសនាមួយការពារផលប្រយោជន៍របស់ជនអារ្យៈនៅប្រទេសឥណ្ឌា កើតចេញមកពីជំនឿរបស់មនុស្សចំពោះព្រះអាទិទេព (ទេវៈ) ដែលគ្មានរូបពិតប្រាកដឋិតនៅត្រង់កន្លែងនៃលោកសន្និវាស...។ល។

## ត្រៃវេទ = វេទ ៣

១– ឫគវេទ Rig véda កើតប្រហែលជា ១០០០ ឆ្នាំមុន គ. ស. គម្ពីរនេះនិយាយច្រើនតែពីពិធីបូជា យជ្ញ (យជ្ញ) បូជាព្រះអគ្និ ។

(ក្តីការពេញគុណ, លើកតម្កើង បូសសើរ) ។

២- យជុវេទ Yadjour véda និយាយកប់របៀបពិធីបូជា យជ្ញ.

៣- សាមវេទ Sâma véda សរសេរជាពាក្យកាព្យ និយាយច្រើនតែអំពីពិធីបូជាទេវតា . . . ។

៤- អថវ៌វេទ Atharwa véda (ខ្មែរហៅក្លាយទៅជា មេកាថាខាងផលខាំឲ្យស បមន្តអាគម) ។

តាមការពន្យល់របស់សាសនានេះ គេនិយាយថា: ព្រះកាទេវតាបានប្រទានគម្ពីរទាំងនេះ (គឺព្រះនាកយណ៍) ឲ្យមកព្រះមនូ (មនូប្រែក្លាយជាមនុស្ស) ព្រះមនូនេះបានពន្យល់ឲ្យដល់ពួកតាបសឫសី តាបសឫសីបានពន្យល់ដល់ពួកព្រាហ្មណ៍ ។ ប៉ុន្តែមានពួកមនុស្សអាក្រក់ គឺយក្សពិកាផងពោះតែមកលួចយកគម្ពីរនេះបានជាពេះតែមានរឿងច្បាំងគ្នាមិនឈប់ ក្នុងហើងដូចជា

រឿងនារាយណ៍ទសាវតារ មានរឿងមច្ឆាវតារ (ត្រី) កូម្មាវតារ (អណ្ដើកកូរទឹកអម្រិត) ព្រះរាមចន្ទ្រនិងវាមនាវតារ (ព្រាហ្មណ៍តឿ) សុំដី ៣ ជំហានក្នុងរឿងត្រៃវិក្រម ... ។ល។ ជាដើម ។

តាមការពិនិត្យមើលចំពោះគម្ពីរវេទទាំងនេះ យើងអាចយល់បានដោយធ្វើការសង្កេតដូចតទៅ :

ក្នុងវិស័យសង្គមកិច្ច : គម្ពីរទាំងនេះបានកត់ត្រានូវចលនានយោបាយដែលគេមានដំណើរទៅប្រវត្តិសាស្ត្រនិងសង្គមកិច្ចនៃពួកអារ្យ (Aryens) ។ ចំណែកខាងជំនឿវិញ គម្ពីរទាំងនេះបានលាតត្រដាងឲ្យឃើញច្បាស់នូវគុណតាបរបស់ព្រះព្រហ្ម ព្រះ-នារាយណ៍និងព្រះឥសូរ (ត្រីមូតិ) ។ បើនិយាយខាងអក្សរសាស្ត្រវិញ គម្ពីរទាំងនេះបានបង្ហាញឲ្យឃើញនូវសភាពឈឺចាប់, កំសត់ទុគ៌ត មានចរិតភ្ជាប់មុខ (fanatique) ក្នុងការបំរើសេចក្ដីប្រាថ្នាដែលខ្លួនមានជំនឿ ក្លាហានក្នុងការអនុវត្តន៍តាមមនោសញ្ចេតនារបស់ខ្លួនក្នុងជំនាន់នោះ ដែលខ្វះការពិចារណាយ៉ាងខ្លាំង ... ។

បន្ទាប់ពីអក្សរសាស្ត្រផ្នែកព្រហ្មនិយមមក នៅប្រទេសឥណ្ឌា ក៏ចាប់ផ្ដើមមានបណ្ដាអក្សរសាស្ត្រផ្នែកពុទ្ធនិយមទៀត ដែលមានមូលដ្ឋានគំនិតនិយមដូចគ្នា ។ ផ្នែកខាងខ្លឹមសារនៃអក្សរសាស្ត្រពុទ្ធនិយមនៅប្រទេសឥណ្ឌា មានបរិតនិងសភាព ប្រហាក់ប្រហែលគ្នានឹងស្រុកខ្មែរយើងដែរខាងមូលដ្ឋាន ខុសគ្នាតែច្រើននៅប្រទេសឥណ្ឌា ប្រជាជនគេកាន់ច្រើនសាសនាណាស់ ហើយសាសនានីមួយៗ ក៏មានច្រើននិកាយថែមទៀតផង ។ គ្រាន់តែសាសនាព្រះពុទ្ធតែមួយ ប្រជាជនគេជឿហើយកាន់ខ្ជាប់ផ្សេងៗគ្នាដល់ទៅ ៧១ និកាយ ហេតុនេះយើងឃើញនៅស្រុកឥណ្ឌា ទៀនអក្សរសាស្ត្ររបស់គេក៏មានបរិបូកប្រែប្រួលមិនសូវឯកភាពប៉ុន្មានដែរ ... ។

ក្នុងបណ្ដាវណ្ណកម្មដែលមានខ្លឹមសារជាពុទ្ធនិយមយើងគាបសង្ខេបយកខ្លឹមសារបានដូចតទៅនេះ ។

អក្សរសាស្ត្រទាំងនោះ ប្រជាមនុស្សស្គាល់ច្បាស់យ៉ាង

ណាដែលហៅថាច្បាប់កម្ម-ផល ព:ធ្លូលតាមប្រាណ ក្នុងវដ្ដ-សង្សារដែលគេហៅថាកន្លែងទុក្ខ ប្រាថ្នាមនុស្សឲ្យយល់ការពិត ៤ យ៉ាង (អរិយសច្ចៈ ៤ Les quatre vérités) ដែលជាមាគ៌ាដឹកនាំមនុស្សទៅកាន់ឋានបរមសុខ គឺព្រះនិព្វាន (កន្លែងដែលគ្មានកើតស្លាប់តទៅទៀត) ។

ក្នុងការសង្ខេបគត្តសនៃបណ្ណាវណ្ណកម្មទាំងនោះ យើងឃើញថា : គោលគំនិតសំខាន់ៗ គឺពន្យល់មនុស្សឲ្យយល់ថា វដ្ដសង្សារ គឺជាសមុទ្រទុក្ខនៃសត្វលោក (កើត, ចាស់, ឈឺ, ស្លាប់) ដរាបណាសត្វលោកនៅមានកើតស្លាប់តទៅទៀតដរាបនោះ សេចក្ដីទុក្ខរបស់សត្វលោករមែងតែបន្តគ្នាឥតចប់ផុត (វិលចុះវិលឡើង) ដោយសារចំណងនៃតណ្ហា Passion (ចង់រស់, ចង់ល្អ, ចង់សប្បាយ, ចង់មាន ...) ចងភ្ជាប់នឹងសម្ភារៈខាងក្រៅ (ពណ៌សម្បុរ, ទ្រដារស, រូបភាព ...) របស់អាត្មន Atman គឺរូបអញ ។

ក្នុងការសង្កេតពាក្យ › អត្តា › អញ › រូប le moi គេ ឲ្យជ្រៅទៅទៀត យើងឃើញថា: បើសិនណាជា «អញ» នេះ បន្តដំណាក់ក្នុងជីវិតតទៅទៀត ៗ

មិនគ្រាន់តែក្នុងមួយជាតិអញនេះប៉ុណ្ណោះទេ ដែលត្រូវ ទទួលទុក្ខក្នុងវដ្តសង្សារ សូម្បីតែជាតិផ្សេងៗ ដែលបន្តពីអញ នេះទៅទៀត ក៏ត្រូវតែទទួលនូវទុក្ខមិនចេះអស់មិនចេះហើយ ដែរ ពីព្រោះគេយល់ថា: លោកនិងទុក្ខ ស្មើនឹងលោក គឺ ស្មើនឹងទុក្ខ ហេតុនេះ បើចង់ផុតទុក្ខត្រូវរកផ្លូវចេញឲ្យផុតពី លោក គឺឋានដែលគ្មានលោក គ្មានរូប សូន្យ ឬហៅថា ព្រះនិព្វាន . . . ៗ គេយល់ថា ការកើតស្លាប់របស់មនុស្ស អន្ទោលទៅវិលចុះវិលឡើង ដូចជាកង់រទេះ អស់មួយជុំទៅមួយ ជុំ . . . មិនមែនស្លាប់ទៅសូន្យឈឹងនោះទេ គឺថាស្លាប់ទៅ ហើយនឹងមកចាប់កំណើតឡើងវិញ មនុស្សដែលមកចាប់កំណើត នោះមិនមែនមនុស្សថ្មីទេ គឺមនុស្សចាស់ៗ ដែលបានស្លាប់ពី

មុខ) ។ ក្នុងខ្ទះឲ្យន័យថា : វដ្ដសង្សារគឺជាកន្លែងមានស្លាប់និងមានកើត ។ យើងឃើញពាក្យថា "មានស្លាប់និងមានកើត" ក៏ខុសគ្នានឹងពាក្យថា "ស្លាប់ហើយមកចាប់កំណើតកើតម្ដងទៀត" ។

គេយល់ថា : ទុក្ខវេទនារបស់មនុស្សជាតិនេះ គឺជាផលនៃកម្មរបស់មនុស្សជាតិមុន ដើមមនុស្សត្រូវតែកើតអំពើមួយដែលគេហៅជាអាក្រក់ទៅក្នុងជាតិនេះ អំពើអាក្រក់នេះនឹងទៅជាផលវិបាកនៃសេចក្ដីទុក្ខក្នុងជីវិតទៅជាតិក្រោយ . . . ។

មនុស្សរស់នៅក្នុងវដ្ដសង្សារ ពិភពលោកមិនទាន់ចេះគេចផុត បំបាត់ទុក្ខបាន គឺជាអ្នកពុំបានកាត់តណ្ហា ដែលបានទុក្ខចេះតែអន្ទោលតាមប្រាជ្ញាណាមិនឃើញសោះ . . . ។

បំបាត់តណ្ហានៅក្នុងលទ្ធិពុទ្ធនិយម មិនមែនសេចក្ដីថា ត្រូវតែរំលាយខន្ធ (រលាយខ្លួន) និព្វាន (គឺស្លាប់) នោះទេ ក្លាយទៅវិញ គឺត្រូវចេះត្រិះរិះពិចារណា តាមផ្លូវសីល, សមាធិ,

បញ្ញា ... គំនិតឲ្យនៅជាកណ្ដាល គ្មានជាប់នឹងសភាវៈអ្វីទាំងអស់ (ទ.បក្ខា) ។ បានសេចក្ដីថា គំនិតជាកណ្ដាល គឺគ្មានការរំភើបចំពោះវត្ថុ ចំពោះសភាវៈអ្វីទាំងអស់ ទោះបីជារីកខ្ទង់ក៏ដោយ ... ។ ភាពលើនេះជាការសង្កេតក្នុងគតិកាល ចំណែកឯរឿងរៀបរាប់ក្នុងសម័យបច្ចុប្បន្ននៃប្រជាជនវៀតណាម ក៏កំពុងតែមានសន្ទុះច្រើន ដូចជាប្រទេសនានាដែលគេកំពុងកាន់សាសនាផ្សេងៗដែរ ទោះបើនៅខ្លួនគេខំពលការរឿងរៀបរយរបស់ពួកបស្ចិមប្រទេសខ្លះៗ នៅឡើយក៏ដោយ ... ។ល។

## ប្រទេសជប៉ុន

ក្នុងការប្រៀបធៀប ប្រជាជនជប៉ុនក៏កាន់សាសនាដែលមានចរិតគំនិតនិយមមិនអន់ណាស់ដែរ ដូចជាសាសនាយ៉ាតូ សាសនាព្រះពុទ្ធផ្នែកមហាយាន ... ។ ហេតុនេះយើងអាចយល់បានថា រឿងអក្សរសាស្ត្ររបស់ប្រជាជនជប៉ុនក៏មានឥទ្ធិពលគំនិតនិយមបែបព្រហ្មញ្ញបែបព្រះពុទ្ធស្រដៀងទៅនឹងខ្មែរ, ចិន, យួន លាវ ... សៀមដែរ ។

古事記

~~Konjaku~~ Kojiki

ក្នុងគម្ពីរកូស៊ីគី ~~KOJIKI~~ (គឺជាក្រាំងកត់សំគាល់នូវរឿងព្រេងផ្សេងៗ ពីបុរាណរបស់ប្រជាជនជប៉ុន) ដែលជាសៀវភៅកត់ទៀបព្រឹត្តិការណ៍ តាំងពីយុគកើតទឹកកើតដីជាមានប្រព័ន្ធទេវតាស្រន្តតាមទស្សន៍ជំនាន់នោះរបស់ជាតិគេ ។

គម្ពីរតាំងនោះបានបញ្ជាក់ឲ្យយើងឃើញថា : កាលដើមឡើយមានបងប្អូនពីរនាក់ ១ ឈ្មោះអ៊ីសាណាស៊ី (ហ្គិ) IZANAGI ១ ទៀតឈ្មោះអ៊ីសាណាមី IZANAMI ត្រូវបញ្ជូនពីស្ថានលើ (ព្រះអាទិទេព) ជាឲ្យចុះមកបង្កើតនគរជប៉ុន ។ បងប្អូនទាំងពីរនាក់នេះបានយកគ្នាជាប្ដីប្រពន្ធ ក្នុងករណីអកុសលប្អូនត្រូវស្លាប់មុនទៅ ចំណែកឯបងនៅរស់ម្នាក់ឯងប្រកើតស្រណោះសោកស្ដាយ ទំដើរទៅគ្រប់ទីកន្លែងដើម្បីរក ប៉ុន្តែមិនប្រទះសោះ ។ ក្នុងពេលចុះទៅងូតទឹកជម្រះកាយនៅក្នុងទន្លេ បងតាំងនោះចេះតែយំសោក... ដល់ពេលឡើងមកលើគោកឯណាក់ត្រាំងវិញ ទឹកសំបោរដែលហូរចេញមកពីរន្ធច្រមុះក៏ក្លាយទៅជាទេវតាគណៈ

អ្នកកាន់ ឬ ខុងជឺ – ទំនៀមគួរតាមចិនផ្សេងការ ទៅជាព្រះអាទិត្យ ទំនៀមកេតាមចិនក្លាយទៅជាព្រះពុទ្ធ . . . ។ល។ ក្រៅពីនេះ នៅក្នុងគម្ពីរនោះមានកក់សំគាល់រឿងរ៉ាវផ្សេងៗ ជាច្រើនទៀតផង ដែលបានបរិយាយលើកតម្កើងសាសនាតៅ ឬជាព្រះអង្គ ដែលបានព្រះអាទិត្យ មិកាដូ ជាកំណើត (Shintoïsme) និងពួកសាសនាដែលគេហៅថា . . .

## បទចម្រៀង Chansons de geste របស់បារាំង

ពាក្យថា geste នេះមានន័យថា : កេរ្តិ៍ជ័យជំនះដ៏កាចកាន វីរបុរសទាំងឡាយ តាមពាក្យ gesta ។

Chansons de geste នេះ គឺជាបទចម្រៀងជ័យជំនះ (ÉPOPÉE) មួយដែលមានចរិតលើកតម្កើងសរសើរបណ្ដាជ័យជំនះដ៏ក្លាហាន ប្រកបដោយពលិកម្មនៃបណ្ដាវីរបុរស ប៉ុន្តែមានលក្ខណៈសម្បើម ទេវតានិយម ឬ ជាគំនិតយល់សប្តិនិយមខ្លះៗ . . . ។ល។

ចម្រៀងទាំងនោះមាន ៣ ប្រភេទ គឺៈ ចម្រៀងវីរកាព្យនៃ ហាក្សត្រ ចម្រៀងវីរកាព្យនៃហ្គីយ៉ូមដូរ៉ង់ Guillaume d'orange ហើយនិងចម្រៀងវីរកាព្យនៃ ដុងម៉ាយ៉ង់ស៍ Don Mayence ។

## ការសិក្សាចម្រៀងរបស់វៀតណាម

ចម្រៀងនិងកាព្យរបស់ជនជាតិវៀតណាម គឺជាកម្រង ពាក្យដែលគួរអោយ គ្មានជំពូក ឬ ក្បួនច្បាស់ ។

អត្ថរសនិងគុណភាពរបស់ចម្រៀងនិងកាព្យទាំងនោះមាន ចរិតប៉ះពាល់ហ្វូងមនុស្សឲ្យគាប់ចិត្តយ៉ាងជ្រាលជ្រៅ ព្រោះមានសំនៀង ទន់ភ្លន់និងការរស់នៅរបស់ប្រជាជនតាំងពីបុរាណមក ។ ទៀនអក្សរ សាស្ត្រដើមរបស់ជនជាតិវៀតណាម និយាយរួមទៅ គឺមិន ខុសពីអក្សរសាស្ត្ររបស់ចិនប៉ុន្មានទេ ខាងរូបភាពក៏ដូចជាមូល- ដ្ឋាន ។ កាលពីដើមមុននឹងមានអក្សរ គុក-ង៉ឺ (គឺអក្សរវៀត- ណាមសព្វថ្ងៃនេះ) ជនជាតិវៀតណាមប្រើអក្សរ « ហាន » (គឺអក្សរចិន) ។ វៀតណាមត្រូវចិនជិះជាន់អស់រយៈ

...ណា ហៅមឿងយ៉ូវទៀតផង ហេតុនេះយើងអាចសន្និដ្ឋានបានថា ទៀនវប្បធម៌ដាំនមូលរបស់វៀតណាម ក៏ជាទៀនវប្បធម៌របស ចិនអ៊ីចិនដែរ ។ ម្យ៉ាងទៀត ពាក្យខ្មែរយើងហៅថាយួន ៗ នេះក៏បានមានឫសគល់ជាប្រវត្តិសាស្ត្រទៀត គឺថាកាលពីដើមយួននេះ គឺជាជនជាតិមួយ ដែលមកពីស្រុកយុនណាន់ YUNNAN ប្រទេសចិនខាងត្បូង ហេតុនេះហើយគាត់ច្រើនទំនៀមទម្លាប់ចិន ឯងវៀតណាម គឺតែងមួយមានអព្យាស្រ័យដូចគ្នា (ថ្ងៃចូលឆ្នាំ, វិធីសែនព្រេន, ដាក់ឈ្មោះកូនទៅយកសែគាយខាងប្ដី . . ។ល។) និយាយសរុបទៅ អក្សរសាស្ត្រ, ទៀនវប្បធម៌, សាសនា . . . របស់ជនជាតិចិន និងវៀតណាមបានសភាពប្រហែលគ្នាណាស់ បើយើងយល់អក្សរសាស្ត្រវៀតណាមច្រើន គឺយើងអាចយល់លក្ខណៈអក្សរសាស្ត្រចិនបានច្រើនដែរ ហើយមានមូលដ្ឋាន...។

## ម៉ាឡាយូ

ទៀនអក្សរសាស្ត្រប្រជាមាតិរបស់ជនជាតិម៉ាឡាយូ រួម-

មានៈពាក្យបណ្ដាំទុកខ្មាន ដែលជនជាតិចាំទុកយូរឆ្នាំ ជាពាក្យ
មានអត្ថន័យការពារទាំងពូកែសក្តិសិទ្ធិ ការពារខ្លួនឲ្យផ្ញើរបាន ។

<u>ចម្រៀង</u> = បទចម្រៀងទាំងនោះមានបរិតលើកសរសើរ
ព្រះអាទិទេព និងលាតត្រដាងថ្វាយព្រះអាទិទេពឲ្យយល់ដឹង
នូវសភាពជីវិតយ៉ាប់យ៉ឺនរបស់ខ្លួន . . ។

<u>ពាក្យបួងសួង</u> = មានពាក្យបួងសួងសុំសេចក្ដីសុខ
សេចក្ដីចំរើនពីទេវតា ខ្មោច អារក្ស អ្នកតា . . ។

<u>ខណ្ឌាកម្មបទ</u> = មានពាក្យពោល ឬ ជាបទចម្រៀង
មានបរិតជាការៈទោសដល់អំពើខុសទាំងឡាយណា ដែលខ្លួនបាន
ប្រព្រឹត្តកន្លងពេលទៅហើយ និងក្នុងពេលដែលខ្លួនបន់ស្រន់ស្នើសុំពរ
ស័ក្តិសារគុណពីខ្មោចព្រាយណ៍ ទេវតា . . ។

# អក្សរសាស្ត្របៀបបូរាណ Classique

អត្ថន័យ – អក្សរសាស្ត្របៀបបូរាណ (ពិសេសនៅប្រទេសអឺរ៉ុប) គឺជាទិន្នការអក្សរសាស្ត្រមួយយ៉ាងដែលត្រឡប់មករករបៀបសរសេរលោកគ្រេកនិង សតិអារម្មណ៍ រៀបតែងគន្ថ ក្រិតវិន័យតាមរបៀបពីដើម... ។

នៅប្រទេសបារាំង ចលនាអក្សរសាស្ត្របុរាណនេះ មានលេចឡើងនៅក្នុងសតវត្សទី ១៧ គឺជាអក្សរសាស្ត្រមួយយ៉ាងដែលត្រឡប់មកយកបែបបទចាស់ពីដើម នៃ ប្រពៃណីរបស់ជនជាតិក្រិក-ឡាតាំង ។ នៅស្រុកខ្មែរយើង ទោះបីជាចលនាអក្សរសាស្ត្រប្រភេទដែលខាងលើនេះ ពុំសូវមានលក្ខណៈលេចឡើងដោយច្បាស់លាស់ នូវរបៀបដូចស្រុកអឺរ៉ុបដោយជាក់លាក់ ការបង្កើតជាចលនាមួយដ៏គ្រប់គ្រាន់ដូចជាប្រ-ទេសគេក្តី ប៉ុន្តែយើងក៏មានស្នាដៃអក្សរសាស្ត្របុរាណសុទ្ធតែចាស់ៗដែលគេទទួលមកពីប្រទេសឥណ្ឌា ប្រទេសចិន... ។ល។

ចលនាអក្សរសាស្ត្របារាំងបែបបុរាណ :

យើងអាចចែកចលនាអក្សរសាស្ត្របារាំងបែបបុរាណជា ៣ ចំណែក (ជំនាន់) ដោយច្បាស់លាស់ គឺ:

១- សម័យមុនរបៀបបុរាណ ១៦០០ – ១៦៥៩

២- សម័យរបៀបបុរាណ ១៦៥៩ - ១៦៨៧.

៣- សម័យរបៀបបុរាណត្រូវអន់ថយ ១៦៨៧ – ១៧១៥.

បណ្ដាការពិសេសៗ នៃចលនាអក្សរសាស្ត្រនេះ គឺ:

ក- ខាងគូរចិត្តមិនមានដំបរិយា គឺថាត្រូវតែប្រព្រឹត្តឲ្យបានត្រឹមត្រូវតាមគន្លងនៃខឿនរបៀបម៉ាំង ទ ក្រិក – ឡាតាំង ។

ខ- ប្រក្ដីកង្វាបារណ៍រឿងរ៉ាវ ឬ ដំណើរកម្មផ្សេងៗ ក្នុងជំនាន់នោះ ពុំមានតម្លៃតែនៅក្នុងផ្នែកអក្សរសាស្ត្រប៉ុណ្ណោះទេ ចំណែកឯខាងផ្នែកសតិអារម្មណ៍ ការណែនាំមនុស្ស . . . គឺនៅតែយកក្បួនក្បាលនៃ សាសនាព្រះយេស៊ូជាមូលដ្ឋានដែលក្នុងការនិពន្ធរឿងពីផ្សេងៗ . . . ។

គេយកសម្មាមតិ (Raisonnement) ជាធំជាក់ពីលើមនោ-សញ្ចេតនា (Sentiment)។ ក្នុងការនិពន្ធគេមិនសូវមានឃើញ ស្មារតីកត្តានិយាយពេកទេ, ការតម្រើនក្នុងបណ្ដាលណ្ដាកម្មចាំងនោះ អ្នកនិពន្ធ ស្ងួតតែប្រគល់ពាក្យសំដីនិយាយឲ្យទៅតួអង្គ ដែលជា-បុគ្គលិកសំដែងរឿង ។

ពាក្យសំដីពេលហ្នឹងត្រូវឲ្យស្មួតបួតខ្លួនសម, និយាយរើសមុខ ឲ្យច្បាស់ ផ្អែមល្ហែម បរេចាសអន្ទ្រលលើកដាក់... ត្រូវចៀស វាងពាក្យសំដីណាដែលថ្មីការណ៍ពិតរោយស្វ័រពេក ។

បើរឿងល្ខោនវិញ ត្រូវតែរៀបរាប់សំដែងឡើងឲ្យស្រប ទៅតាមក្បួនដែលគេហៅថា "ត្រីសណ្ឋាន" ឬថា "ឯកភាព ៣ យ៉ាង" trois unités គឺ :

១ – ឯកភាពទីកន្លែងដែលកើតមានរឿងនិមួយ ៗ Unité de lieu.

២ – ឯកភាពពេលវេលាដែលកើតមានរឿងនោះ Unité de temps,

៣- ឯកភាពចលនានៃផ្លូវរឿង Unité d'action គ្រប់ប្រភេទវណ្ណកម្មត្រូវតែញែកឲ្យច្បាស់លាស់ រឿងរ... មិនត្រូវឲ្យលាយឡំនឹងជ័យជំនះវីរភាព ÉPOPÉE រឿងចំអកថ្លង (Satirique) មិនត្រូវឲ្យលាយឡំ ប្រឡូកប្រឡល់នឹងរឿងអត្ថា-ធិប្បាយ ... ។ល។

យូរៗមានផ្នែកវណ្ណៈទាំងពួកគេមានស្តេចនាម៉ឺនជាដើមទៀតឱកាសដើម្បីពង្រឹងបុព្វសិទ្ធិអំណាចរបស់ខ្លួន ពួកកវីនិពន្ធសិល្បករក៏ប្រែក្លាយខ្លួនទៅជាពួកចុកផ្លុំកំព្រៀង បណ្តាវណ្ណកម្មទាំងនោះគ្មានចរិតប្រជាមានិត គឺជាវណ្ណកម្មដែលលើកសរសើរវណ្ណៈទាំងពួកគេ ... ។ល។

# អក្សរសាស្ត្របែបបុរាណរបស់ខ្មែរយើង

ដើរទន្ទឹមគ្នានឹងរឿងអក្សរសាស្ត្ររបស់ប្រជាជនយើង ពីសម័យដើម ( សម័យមុនលទ្ធិព្រាហ្មណ៍ចូលស្រុក ) កាលនោះខ្មែរយើងមិនទាន់មានអក្សរនៅ គេប្រើនិយាយផ្សាយតៗគ្នា តាមមាត់ទៅៗ ។ — ចលនាអក្សរសាស្ត្របែបបុរាណដែលផ្សាយចេញមកពីឥណ្ឌាក៏ចាប់ផ្តើមមានតាំងពេល ហើយមុនដំបូងប្រើអក្សរជាសំស្ក្រឹត ( នៅលើសិលាចារឹក ) កត់ត្រាសំគាល់ហេតុ គេ ឬ ព្រឹត្តការណ៍ផ្សេងៗ ជាអក្សរសំស្ក្រឹត ។

លោកស៊ឺដេស ចាងហ្វាងសាលាបូព៌ាប្រទេសបារាំងបាន ថ្លែងថា : ភាសាសំស្ក្រឹតជាភាសាអ្នកប្រាជ្ញសម្រាប់ធ្វើបញ្ជីកត់ត្រារឿងហេតុរបស់ស្តេច ( នៅឥណ្ឌាគេយកទៅប្រើសម្រាប់តែងកាព្យ ) សេចក្តីផ្សាយតែងជាភាសាសំស្ក្រឹតសុទ្ធតែរៀបរៀងជាពាក្យកាព្យ មានក្បួនខ្នាត ក្រិត្យក្រមទំនងត្រឹមត្រូវ ... ។

វណ្ណៈកម្មផ្សេងៗ ច្រើននិយាយសរសើរលើកតម្កើងវណ្ណៈខ្ពង់ពួកដែលបួសមុនចេញមកពីប្រទេសឥណ្ឌា ដូចជារឿង

ទាក់ទិនសាវតារ... ជាដើម យកមកផ្សាយកាប់សង្ខាប់ម៉ានមន្តអាគមតាមគម្ពីរវេទ ។

បន្ទាប់ពីនោះមកក៏មានអក្សរសាស្ត្របែបបូរាណ ដែលផ្សាយជាភាសាមគធៈទៀត ដូចជារឿងជាតកនៅក្នុងគម្ពីរបាលីបូរាណ ... ។ យកច្បាប់កម្មផល loi de la causalité នៃព្រះស្រាយសេចក្ដីសុខទុក្ខ យកជំនឿមកទប់ទល់នឹងការវេទនាលំបាកនឹងយកលទ្ធិសក្ដិភាពនិយមមកដោះស្រាយ ទំនាស់តាមពុទ្ធសាសនា ... ។

ក្រៅអំពីនោះ រឿងបែបបូរាណដែលមានបកប្រែជាខេមរក៏សន្ធឹកណាស់ដែរ រឿងទាំងនោះមិនសូវមានតម្លៃជាអក្សរសាស្ត្រទេ ពីព្រោះពីដើមមកគេមិនសូវមានកត់ត្រាជាសៀវភៅឬក្រាំងផ្សេងៗ រឿងទាំងនោះគេច្រើននិយាយប្រាប់គ្នាតៗ តាមមាត់ ហើយគេអ្នកនិពន្ធក៏មិនឃើញផង ។ ប៉ុន្តែ ទោះបីឃ្លោឃ្លោងមិនសូវបានត្រឹមត្រូវ គ្មានលក្ខណៈអក្សរសាស្ត្រ ក៏ដោយ

កំរឿងទាំងនោះពុំមានអត្ថរស គឺជាតម្លៃសតិអារម្មណ៍ល្អប្រើទក្នុងការណែនាំមនុស្សទៅរកសេចក្ដីសប្បាយ សេចក្ដីសុខហើយមានសោភ័ណភាពទៀតផង ដូចជារឿង «សិស្សនឹងគ្រូ, រឿងផុតពុកកើសកូនប្រុសា, កាឡៅ, ផនញ័យ ... ។ល។

# ការបដិវត្តន៍អក្សរសាស្ត្រ

ក្នុងករណីមានការប្រែប្រួលធំដុំជាប្រវត្តិសាស្ត្រខាងអង្គការនយោបាយ, អង្គការសេដ្ឋកិច្ចនិងវប្បធម៌សង្គមកិច្ចផ្សេងៗ . . . ការប្រែប្រួលខាងអក្សរសាស្ត្រក៏គេឃើញមានលេចឡើងដែរ ។

នៅប្រទេសបារាំង ការបដិវត្តន៍អក្សរសាស្ត្រមានកើតឡើងនៅក្នុងសម័យរៀនវិវត្តន៍ Epoque de la Renaissance ក្នុងសតវត្សរ៍ទី ១៦, ១៧ បន្ទាប់មកទៀតដល់ការកែប្រែសាសនា ដល់ការចលនាអក្សរសាស្ត្រមហាវិជ្ជាសមោធានជំនាន់ Diderot.

នៅប្រទេសចិន ការបដិវត្តន៍អក្សរសាស្ត្រមានលេចឡើង បន្ទាប់ពីការបដិវត្តន៍នយោបាយឆ្នាំ ១៩១២ រំលំពួកសៀវ-ម៉ាន់-ជាន់ ។ បន្ទាប់មកមានអស់លោក ហោ-ទី ឧិន ស៊ួច-ម៉ាំកញៀក ធ្វើបដិវត្តន៍អក្សរសាស្ត្រ និងពង្រីកពង្រឹងថែមបន្តបន្ទាប់គ្នា . . . ។

នៅស៊ូវៀត បន្ទាប់ពីបដិវត្តន៍ខែ ១០ មក នៅប្រទេស

មានក្រោយៗ បន្ទាប់ពីឆ្នាំ ១៨៩០ នៅវៀតណាម ក្នុងកម្ពុជាឆ្នាំ ១៩១៨ និងនៅប្រទេសខ្មែរយើង បន្ទាប់ពីសង្គ្រាមលោកលើកទី ២ មក ។

## លក្ខណៈពិសេសនៃការបដិវត្តន៍

បដិវត្តន៍អក្សរសាស្ត្រមិនមានន័យថាបង្កើតបលនា អក្សរសាស្ត្រក្នុងក្តាំងក្នុងមួយពេល ហើយមានបរិតឯកជនទាំងស្រុង ទាំងក្រុមៈតារាង និងពេលផល់ការបដិវត្តន៍អក្សរសាស្ត្រ គឺយើងត្រូវនិយាយផលល់មកពេលទាំងអស់គ្នា មានគំនិតកែប្រែក្នុងរយៈមួយយ៉ាងវែង ធ្វើឱ្យអក្សរសាស្ត្រមានលក្ខណៈស្របនឹងការទាមទាររបស់មនុស្ស ស្របនឹងសមត្ថភាពរបស់ប្រជាករ ។ល។ មានសតិអារម្មណ៍ជឿនលឿន មានគំនិតដឹកនាំទៅរកសុភមង្គល និងត្រូវប្រើពាក្យពេចន៍ងាយៗ មានចរិតប្រជា[illegible]និក ។

<u>គោលដៅនៃការបដិវត្តន៍</u> ៖ គោលដៅនៃការបដិវត្តន៍អក្សរសាស្ត្រនៅពេលកន្លងទៅមានដូចនេះ គឺ ៖

– ដើម្បីវាយបំបាក់ពៃចាស់ បំបាត់របៀបសរសេរវិធី បុរាណសេចក្តីតិច តែរកពាក្យសំដីតាមច្បួកគកិជន ។

– ដើម្បីពង្រីកការសរសេរនិពន្ធមានប្រយោជន៍ ដល់ មហាជនទូទៅ ... ។

– ដើម្បីវាយបំបាក់គំនិតលោកគ្រូជាន់ការពិត តែមិនហ៊ាន និយាយចំៗ (និយាយវៀចវេរ) តាមរបៀបបុរាណចារិក ...

littérature classique.

– ដើម្បីពង្រីករឿងអក្សរសាស្ត្រលោកិយសច្ចៈ និយាយ ការពិត (Vérisme) ដោយរបៀបសរសេរថ្មី រក់ហ្វាញ្ញាស់ជឿន លឿនហើយស្មោះត្រង់ ... ។

– ដើម្បីវាយបំបាក់គំនិតការនិយាយធ្វើឲ្យលំបាក, (មានការ ប្រើភាសាពិបាកយល់ដល់មហាជន ) ពិបាកយល់ដោយប្រើពាក្យ មិនទូទៅ ។

– ដើម្បីពង្រឹងរឿងអក្សរសាស្ត្រជាតិ ឲ្យមានបរិសុទ្ធិ និងបាន មានលក្ខណៈខ្ពស់ហើយក៏ស្អាត ... ។

និយាយរួមទៅគឺថា៖ វេចនិយាយ របៀបសរសេរតាមវិធីកែប្រែថ្មី គឺជាងាយយល់, ច្បាស់លាស់, មិនសូវមានពាក្យពិបាក ងាយស្រួលផ្សព្វផ្សាយទៅដល់មហាជនពលករ. ហេតុការណាមានការប្រែប្រួលក្នុងសង្គមថ្មី ៗ ការប្រែប្រួលនេះ រមែងមានគុណភាពធ្វើឲ្យសតិអារម្មណ៍របស់មហាជនបានល្អលាស់ បេះដូងថែមនូវព្រឹត្តិការណ៍ផ្សេងៗ, ចលនាបាននូវគំនិតបង់បេះ ជីវិតនិស្ស័យនយោបាយ ដែលជាកត្តាមួយជួយជម្រុញរឿងអក្សរសាស្ត្រឲ្យបានជឿនលឿនថែម ដែលជាហេតុនាំឲ្យខ្លួនគាត់តែភ្ញាក់ពេកនូវផលប្រយោជន៍ជាតិបានច្រើនឡើង ។

# ចលនាអក្សរសាស្ត្រតាមទំនើង ?

អត្ថន័យ = ពាក្យថា «តាមទំនើង» (Baroque) មកពីពាក្យអេស្ប៉ាញ៉ុល (Espagnol) ថា Barucco មានន័យថា «ស្មុញស្មាញ ឬ ក្រវើមក្រវឹម» ។

អក្សរសាស្ត្រតាមទំនើងមានគោលបំណងប្រឆាំងនឹងស្ថាក-ការវិធីសាស្ត្រឯកទេស(១) វេយ្យាករណ៍និយមកែមកែគ្រឿងក្បៀក-បន្សៀកបន្តួលក្នុងអក្សរសាស្ត្រ ដើម្បីរំដោះឲ្យមនុស្សខ្មែរសេរី-ភាពទាំងស្រុងតែងជួបជាមួយនឹងទោសវេទនា... ឲ្យទាន់ល្បឿនសិល្បៈក្នុងសម័យរ៉ឺណេសង់ (Renaissance) នៅប្រទេសបារាំង ក៏ដូចជាប្រទេសអ៊ីតាលីក្នុងសម័យសតវត្សរ៍ទី ១៥, ១៦ ។

ឧបហេតុ ២ ហេតុដើមដែលនាំឲ្យមានជាព្យាករណ៍ចលនាអក្សរសាស្ត្រតាមទំនើង, មកអំពីរឿងអក្សរសាស្ត្រវេយ្យាករណ៍និយម(២) វិធីសាស្ត្រឯកទេសដែលកែគ្រឿងបន្តិចបន្តួចសេរីភាពនៃការនិពន្ធរបស់ពួកកវីសិល្បករអក្សរសាស្ត្រ ។

---

១– បេះតែដើរតាមគ្នាតាមទិសតែមួយ ។

២– វេយ្យាករណ៍ហួសហេតុ ។

មកអំពីគ្រឿងវិទ្យាសាស្ត្ររីកចំរើន ក៏បាននាំមកឲ្យមនុស្សជំនាន់នោះនូវស្មារតីស្រេកឃ្លានសេរីភាព ស្មារតីរំដោះនិងគតិសិក្ខាបទនិយម (Dogmatisme) ។

– មកអំពីចលនាវប្បធម៌ក៏បានស្ទុះទៅរីកបរិបូណ៌ទៅគ្រប់វិស័យ .. ។ មានអ្នកណានាំដើមប៉ុនដូចជាលោក Le correge Raphaël Michel Ange .. មុនដំបូងរីកចំរើននៅស្រុកអ៊ីតាលីក្នុងចំណោមពួកសាសនាក៏ដូចជាប្រជារាស្ត្រខាងក្រៅ ។

<u>វត្ថុបំណង</u> = ចលនាគតិសាស្ត្រតាមទំនើបមានគោលបំណង :

១– ខាងវិស័យសតិអារម្មណ៍ គឺគោរពតាមរបៀបបុរាណជំនាន់ក្រិក-ឡាតាំង ដើម្បីស្វែងរកតម្លៃនៃសេរីភាពនៅក្នុងគម្ពីរសាស្ត្រ ។ តែឲ្យខាងរឿងវិទ្យាសាស្ត្រ ដើម្បីធ្វើឲ្យមនុស្សមានសេរីភាពក្នុងការពង្រីកសម្មាធិ (Raisonnement) សេរីភាពឯកជន និងសេរីភាពខាងជំនឿ . . . ។ល។

២– ក្នុងវិស័យសាសនាគ្រិស្ត គឺណែនាំចិត្តឲ្យចេះ

ស្រឡាញ់ធម្មជាតិ  ស្វែងរកសោភ័ណភាពនៃសម្រស់ធម្មជាតិ មនោសញ្ចេតនាបានដោះស្រាយ ។ សិល្បៈមាននាទីធ្វើឲ្យបានចូលធ្វើអន្តរកម្មនៅគ្រប់វិស័យនយោបាយ, ទស្សនវិជ្ជា, សេចក្ដីស្នេហានិងជីវភាពកាលថ្ងៃនៃសង្គម... ។ ម្យ៉ាងទៀតត្រូវឲ្យមនុស្សមានសេរីភាពក្នុងការចូលចិត្តតាមចំណង់នៃឯកជនម្នាក់ៗ មាននូវសេរីភាពក្នុងការបង្កើត ឬ ស្ថាបនា មានសេរីភាពបណ្ដុះកម្លាំងឲ្យមនុស្សទៅវិញទៅមក ។

និយាយសង្ខេបមកគឺថា : « បណ្ដាឋានពលរបស់មនុស្សក៏ជាទីបំផុតគប្បីបានមកជាកម្មសិទ្ធិនៃឯកជនម្នាក់ៗ, ពង្រីកសេរីភាពឯកជនឲ្យដល់កម្រិត មនុស្សត្រូវប្រើគ្រប់មធ្យោបាយដើម្បីត្រឡប់មករកសោភ័ណដ៏ឯក (សោភ័ណនិយម) តាមបែបឡង់-សុង (Lanson). ។

<u>មធ្យោបាយអនុវត្តន៍</u> = ដើម្បីអនុវត្តឲ្យបានតាមគោលបំណងរបស់ខ្លួន អក្សរសាស្ត្រផ្នែកទំនើបនេះ បានដាក់ទិសការនិពន្ធដូចតទៅ :

— និពន្ធរឿងជ័យជំនះ  វីរភាពមានចរិតក្លាហានដើម្បី លើកតម្កើងវីរភាពថ្លៃថ្នូរជំនាន់បុរាណ ។

— ចម្រៀងប្រទិតឡើង (ចម្រៀងកប់រៀប) មានចរិត លើកតម្កើងវីរភាពពលករ  វីរភាពកាយចំរើន . . . ។

និពន្ធអត្ថបទមានលក្ខណៈរិះគន់ដល់ខ្មាំងចាស់ដើម្បី ធ្វើឲ្យមនុស្សសប្បាយនឹងជំនួនដល់របៀបពីដើម . . . ។

— និពន្ធអត្ថបទទំនៀមដល់អក្សរសាស្ត្រសុទ្ធកែ និងសត្វៈ ជមិ ។

— និពន្ធបទចម្រៀងពិរោះៗ យ៉ាងស្រនេះស្រនោចអន្ទង់ អន្ទាប  អណ្ដែតអណ្ដូងទៅក្នុងពួកសាសនា  កំដូជាប្រជាករ ទូទៅ ។  ប៉ុន្តែបន្ទាប់មកបណ្ដាមជ្ឈជានមហោបាយ តាំងឲ្យពាយ បាននៀតចកាសល្អក់យំបាក់បលនាអក្សរសាស្ត្រជន់ «គាយ ទំនើន» នេះឲ្យបរាជ័យទៅ ។

ក្នុងករណីត្រូវពួកទស្សនទិទ្ធ  និងពួកទេក្ខាទិយមប្រឆាំង

ទប់ទល់យ៉ាងខ្លាំងគ្រប់វិស័យនយោបាយ, សេដ្ឋកិច្ច, សតិអារម្មណ៍, វិទ្យាសាស្ត្រ ... ពួកវណ្ណៈខ្លាំងពួកមានគ្រួសារអភិជន នាម៉ឺន ស្ដេចបានធ្វើឲ្យចលនាអក្សរសាស្ត្រ "តាមទំនើង" នេះក្លាយទៅជាសភាវៈបូកណហួសសម័យ (Rococo) ហើយនៅទីបំផុត ចលនាបែប "ទំនើង" នេះ Baroque ក៏ខូត នាំឲ្យចលនាអក្សរសាស្ត្របែបប្រលោម (សេរីភាពនិយម) Romantique បន្តបេសកកម្មជំនួសបុគទៅទៀត ។

# អក្សរសាស្ត្រប្រលោមលោក (Romantique)

# ឬ អក្សរសាស្ត្រសេរីនិយម (Libertin)

អត្ថន័យ = អក្សរសាស្ត្រប្រលោមលោកមានចរិត ៤ យ៉ាងជាមូលដ្ឋាន គឺ. មានលក្ខណៈស្នេហា, ពាក់ទងដល់មនោសញ្ចេតនា, ឯកជននិយម និងមានចរិតនាំឲ្យអ្នកអានស្រវឹងចូលចិត្ត ។ លក្ខណៈពិសេសរបស់គឺស្នេហា និយាយអំពីការលាតត្រដាងនូវមនោសញ្ចេតនាទាំងអស់ដែលកប់ក្នុងនៅក្នុងចិត្ត ហេតុដូច្នេះ អក្សរសាស្ត្របែបប្រលោមលោកមាននិតិការលាតត្រដាងបញ្ចេញមកក្រៅ នូវមនោសញ្ចេតនា នូវបណ្ដាសមានចិត្តនៃបុគ្គលនីមួយៗ និងបណ្ដាសោភ័ណភាពល្អស្រស់ស្អាតជាទីចាប់អារម្មណ៍ខ្លាំង ។

ខាងផ្នែកទម្រង់ អក្សរសាស្ត្រប្រលោមលោកមានពាក្យពេចន៍យ៉ាងប្រណីតពីរោះនិងបណ្ដារូបភាព វិធីអក្សរសាស្ត្រវិតវូតជំនាន់បូរាណ ខាងផ្នែកអត្ថរស ផលនាប្រលោមលោកបានលំដោះឲ្យមនុស្សមានមនោសញ្ចេតនាសេរីភាព គ្មានការរិតត្បិត

តាមទម្លាប់ ឬ វិធីនិយម និយាយមួយបែបទៀតថា: ចលនាប្រលោមគឺជាមធ្យោបាយជាប់ថ្មីមួយហៅថា គួរឲ្យការណាននឲ្យទៅដល់ចលនាជាក់ស្តែងនិយម (Réaliste) និងនិម្មិតក្នុងអក្សរសាស្ត្រ Vérisme ព្រមទាំងលទ្ធិសោភ័ននិយម ក្នុងវិទ្យុ-

. . . ។

បណ្ដាអ្នកនិពន្ធទាំងអស់ត្រូវគេនិយាយ បំពេញចលនាប្រលោមលោកជាអក្សរសាស្ត្រ :

- ផ្ទុយទៅនឹងមនោសញ្ចេតនា រហូតដល់នឹងបញ្ញាមតិ (Raisonnement) ។

- ផ្ទុយទៅនឹងឯកជនភាព រហូតដល់នឹងសង្គមជាតិ ។

- ផ្ទុយទៅនឹងគំនិតស្រមៃ imagination រហូតដល់ការជាក់ស្តែង ។

- ផ្ទុយទៅនឹងធម្មជាតិភាព រហូតដល់ការតស៊ូក្នុងជីវិតមនុស្ស ។

គេអាចចែកចលនាអក្សរសាស្ត្រប្រលោមលោកជា ២ ប្រភេទផ្សេងគ្នា :

១– ប្រលោមលោកជឿនលឿន = ទោះបីមានចរិតស្នេហាខ្លះ ប៉ុន្តែគេយកស្នេហាជាមធ្យោបាយចលនាចិត្តមនុស្សឲ្យបំរើការចលនារបស់សង្គមនិយាយរួម គឺមានជីវភាពខាងស្មារតីក៏ដូចជាខាងសម្ភារៈរបស់សង្គមជាដើម . . . ។

២– ប្រលោមលោកពុករលួយ = ដើរតាមជនទន់ស្នេហាដើម្បីស្នេហា បុគ្គលនិយម មានចរិតលយធាយពាសកាលខុសនិងគ្មានសម្អាងហេតុ Raisonnement ស៊ីបន្តបរសាងក្នុងការសប់កសាង . . . ។

មានអ្នកខ្លះឲ្យន័យប្រលោមលោកថែមមួយប្រភេទទៅទៀត គឺថា « ប្រលោមលោកបដិវត្តិ (Romantisme Révolutionnaire) ។ បើតាមលោកមហាកវីនិពន្ធទៅម្នាក់ឈ្មោះ ម៉ាក់ស៊ីមគ័រគី Maximegorki លោកនេះមានយោបល់ថាចលនា

អក្សរសាស្ត្រប្រលោមលោក គឺគ្រាន់តែជារូបភាព ១ បែបនៃជឿនអក្សរសាស្ត្រធម្មសច្ចៈរបស់សង្គម (Réalisme social) ប៉ុណ្ណោះទេ ... ។

## ចលនាប្រលោមលោកនៅបស្ចិមប្រទេស

ចលនាអក្សរសាស្ត្រនេះកើតឡើងតាមល្បឿននយោបាយសេរីនិយម តាមជឿនសេដ្ឋកិច្ចឧស្សាហកម្មសេរីនិយម ក្នុងករណី ដែលវិទ្យាសាស្ត្រចាប់ផ្តើមលូតលាស់ជាបឋម ។ ទស្សន៍ J.J. Rousseau ជាពលករដើមដំបូងក្នុងការលើកទង់និងការរៀបចំឲ្យបានជាប្រភេទមួយ ដែលហៅថាប្រព័ន្ធប្រលោមលោក (Système romantique)

ចាប់ផ្តើមពីពេលនោះមក ចលនាប្រលោមលោករឹតតែរីកចំរើនមានសន្ទុះយ៉ាងខ្លាំង ហៀរហូរចូលទៅក្នុងវិស័យវេទិការ សិល្បៈ និងវប្បកត្រ្តិយ៍ ... ។ Lamartine, Alfret de Vigny, Victor Hugo, Alfret de Musset អ្នកដឹកនាំនេះបានចូលក្នុងប្រលោមលោកនៅបស្ចិមប្រទេសមុនគេបង្អស់ ។

# បណ្ដាប្រលោមលោកនៅប្រទេសខ្មែរយើង

បណ្ដាប្រលោមលោកមានកប់ពួន នៅក្នុងរឿងអក្សរសាស្ត្ររបស់ជាតិយើង តាំងពីសម័យបុរាណមក គឺជាចាប់តាំងពីក្នុងកម្ពុងសតវត្សរ៍ទី ១៧ ម៉្លេះ ប៉ុន្តែជាពិសេសរឿងប្រលោមទាំងនោះមិនសូវមានចរិតជាតិទេ ភាគច្រើនគឺបកប្រែ ឬ ដកស្រង់ចេញមកអំពីឯកសារគម្ពីរផ្សេងៗ មានគម្ពីរតាមបែបព្រហ្មសាសនានឹងពុទ្ធសាសនាជាដើម ... ។ ប៉ុន្តែដល់មកពាក់កណ្ដាលសតវត្សរ៍ទី ១៨ ក៏មានលេចឡើងដោយច្បាស់លាស់នូវបណ្ដាប្រលោមលោកខ្លះៗ ដែលមានលក្ខណៈជាតិពិតប្រាកដ ដូចជារឿងទុំ-ទាវ ទៅមាស ... ។ល។

ចលនាអក្សរសាស្ត្រខ្មែរផ្នែកប្រលោមលោក មានរូបរាងច្បាស់លាស់មានអត្ថរសជឿនលឿនខ្លះ ក្នុងការប្រៀបធៀបជាមួយនឹងរឿងបុរាណ គឺចាប់តាំងពីក្បាលសតវត្សរ៍ទី ២០ មក ទោះបីពួកអាណានិគមនិយមបារាំងរឹតត្បិតសកម្មភាព ខ្ទប់មាត់ខ្ទប់ច្រមុះយ៉ាងណាក៏ដោយ ។

# ចលនាអក្សរសាស្ត្រក្រមាប់កំប្លែង Satirique

គោលបំណង= ទិសដៅនៃចលនាអក្សរសាស្ត្រនេះ គឺរកមធ្យោបាយលាតត្រដាងនូវការអាក្រក់, ការខុសឆ្គាំឆ្គង, ការគាំទប្រឡំជាគុណវិបត្តិនៃមនុស្សដ៏វៃរដោយស្លាបប៉ាំការ ពាក្យសំដីមានចរិតលេងកំប្លែងសើចសប្បាយ ឬ គ្រគោះគ្រគំខ្លាំង ដោយសំនួនវោហារក្នុងបរិះគន់ ដើម្បីកសាងកែប្រែ ឬ ដើម្បីបន្តុះផ្ចាញ់ផ្ចាល ... ។

# ការបែងចែកចលនាអក្សរសាស្ត្រក្រមាប់កំប្លែង

អនុលោមទៅតាមតម្លៃនៃការស្វែងលាតត្រដាងចិត្តសាស្ត្រ និងតម្លៃគំនិតក្នុងការជួយកែប្រែអប់រំគ្នាទៅវិញទៅមក គេអាចចែកចលនាអក្សរសាស្ត្រនេះជា ៤ ប្រភេទ ដូចជា :

១- ប្រភេទក្រមាប់ Satire= គឺជាវិធីក្រមាប់ដោយប្រើពាក្យប្រាសផ្ទុះយ៉ាងស្លូន ដើម្បីលាតត្រដាងពុតអាក្រក់ បង្ហាញគំនិតដោកនៃអ្នកណាមួយ ក្នុងគោលបំណងសំគុយមនុស្សមានទោសទឹងបង្កើតមេរៀនឲ្យមនុស្សជុំវិញ ដែលជា

ឥទ្ធិពលល្អរបស់ខ្លួន ... ។ ហេតុដូច្នេះ អ្នកនិពន្ធប្រភេទរឿងល្ខោនត្រូវយល់ឲ្យអស់យ៉ាងច្បាស់ នូវគុណវិបត្តិនិងចំណុចខ្សោយនៃប្រជាជន ដើម្បីកែវិធីបញ្ចេញបញ្ចូលក្នុងការអធិប្បាយ កុំឲ្យមានការញ៉េះញ៉ើតញ៉េះញ៉ើមគេះអុញ ... ។

២- ប្រភេទឈរផ្អាប់ Farce = មិននិយាយឲ្យចំការពិតទាំងស្រុងពេកទេ និយាយតែគុណវិបត្តិតូចតាច បញ្ចិតបញ្ចៀង ប៉ុន្តែមានធ្វើកាយវិការប្លែកមុខក្លែងៗ បែបស្នុយប្រូកប្រោយចាក គួរឲ្យអស់សំណើច ... ។ វិធីនេះស្រាលជាងវិធីរឿងល្ខោននោះក្នុងការរិះគន់ផ្ទាត់ក៏ដូចជាការកេងសាកសប៉ះ ... ។

៣- ប្រភេទចំអក ( ផ្ទុញផ្ទាល់ Ironie = ធម្មតាច្រើនប្រើគំនិតផ្ទុយចំអកផ្ទួញផ្ទាល់នៅក្នុងឃ្លារឿងល្ខោន បានសេចក្តីថា: បញ្ចិតបញ្ចៀងនិយាយរឿងនេះ នាំឲ្យគេនឹកដល់រឿងនោះ និយាយឯកើតនាំឲ្យឈឺដល់ឯត្បូង ... ។

វណ្ណកម្មប្រភេទនេះ ទើបនឹងមានក្លាយឃើញបែបដូចជា

ផ្គួសផ្កាសស្លូកស្លឹង ប៉ុន្តែផល់យល់ឲ្យជ្រៅទៅ, ពិតឲ្យផល់ទៅទើបឃើញថាស្នែងជួរចក់គួរឲ្យសើច, គួរឲ្យឈឺចាប់អន្ទះលោមះទៅតាមសមត្ថភាពនៃអ្នកស្ដាប់ ឬ អាន . . . ។ កាលណាយើងប្រមូលបានអត្ថន័យមក ទើបឃើញអត្ថរសដ៏ស្ងាប់លេចឡើង ។ ហេតុនេះហើយ អ្នកនិពន្ធប្រភេទនេះត្រូវចេះស៊ីជម្រៅ មានពាក្យពេចន៍ច្បាស់លាស់ យល់ឲ្យទូលាយហើយមិនភ្ញាក់ផ្អើលចិត្តស្រាល . . . ។

<u>៦ – ប្រភេទសិល្បគតិ Esprit =</u> ត្រឹមត្រូវនិងពិតមានគតិបណ្ឌិត ។ អ្នកនិពន្ធប្រភេទនេះមានទស្សនៈទូលាយចូលទៅចំពោះករណីអ្វីមួយ ប្រើគំនិតគួរសមញ្ញស្របតាមផ្លូវចិត្តតាមផ្លូវមនោសញ្ចេតនា បែបដូចជាប្រភេទកាសិត ឬ ពាក្យចាស់ទុំនាន . . . ។ មានជួនកាលអ្នកនិពន្ធដាក់ចេញជាពាក្យមានបរិតជាវិធាន (loi) ឬ ជាច្បាប់របស់សង្គម ដោយសារការពិសោធន៍ពីមុនមកថែមទៀតផង ។ និយាយសង្ខេបទៅគឺថា :

ប្រភេទចំអក ទំនងប្រភេទសិល្បគតិមានសភាពទឹងទំនឹង ស្ងាត់ស្ងៀម សម្លាយរឹតកាយនៃស៊ីជម្រៅ ៗ ប្រភេទរឿងល្ខះមានសភាព ឈឺចាប់ផ្សូងតក្តៅក្រហាយ . . . ប៉ុន្តែនិយាយរួមទៅ គឺមានអត្ថន័យ ៖

- ច្រាសជ្រៅជាងចាសនាបែបប្រពៃណីលោក.
- មានការរិះគន់រឿងបែបថ្មីរួចស្រាល ជាប្រភេទសច្ចៈនិយម (Réalisme) ច្រើន
- បែបថ្មីជាប្រភេទរិះគន់វិទៀន ៗ

# អក្សរសាស្ត្រតាមនិន្នាការអត្ថិភាពនិយម Existentialisme

និន្នាការតាមបែបលទ្ធិអត្ថិភាពនិយមបានផុសពន្លកពីយូរមក-ហើយ ៗ លោក J.P. Sartre បានថ្លែងថា: ក្នុងសតវត្សទី ១៨ Diderot, Voltaire, Kant សុទ្ធតែមានទស្សនៈអត្ថិភាពនិយមបានចាត់ចោលគំនិតសាសនានិយម ៗ ហួសមកដល់ពាក់កណ្តាលសតវត្សទី ២០ (១៩៣៩-១៩៤៥) ទើបលោកហ្សង់-ប៉ូល. សាត្រ៍ (J.P. Sartre) បានច្រើនឡើងដោយរូបភាពទស្សនវិជ្ជា និងអក្សរសាស្ត្រយ៉ាងហ្មត់ចត់ ៗ

គោលបំណង= នៅក្នុងបណ្តាវណ្ណកម្ម បានដៃ ក្រខ្វក់ "Les Mains Sales" "Les Jeux sont Faits" "La P . . . Respectueux" ពិសេសក្នុងសៀវភៅ "សត្វ" និង "សូន្យ" ៗ

ទ្រឹស្តីអត្ថិភាពនិយម គឺជាលទ្ធិមនុស្សនិយម (ប្រឆាំងនឹងលទ្ធិគំនិតនិយមជំនាន់បុរាណ) Anthropologisme J.P. Sartre បានបញ្ជាក់ច្បាស់លាស់ថា "យ៉ាងណាដែលហៅថា អត្ថិភាព-និយម?" ៗ

- គឺសភាវៈទាំងអស់សុទ្ធតែមានពីរផ្នែកសំខាន់ គឺ: វត្ថុធាតុ (Essence) និងការធរមាន (Existence) ។

វត្ថុធាតុមុនមានបណ្តាសភាវៈទាំងអស់ដែលមិនប្រែប្រួលរបស់មនុស្ស ការរស់មានជីវិត (ធរមាន) គឺជាសភាវៈមួយដែលមាននៅក្នុងបច្ចុប្បន្ន ។ សាសនា, ទស្សនវិជ្ជា, ទំនៀមទម្លាប់ ហើយពិសេសបណ្ឌិតអ្នកចេះដឹងទាំងអស់នៅមហាវិទ្យាល័យ សរ-បោន Sorbonne ក៏សុទ្ធតែទទួលស្គាល់ថា: វត្ថុធាតុមានមុនជីវិតដែរ ។ ហេតុនេះមនុស្សត្រូវខ្វល់ខ្វាយផល់អតីតកាលដើម្បីស្វែងរកអនាគតល្អ .. ។

ពួកវត្ថុភាពនិយមមានគោលគំនិតបោះបង់ទេវតានិយម ពីព្រោះគេយល់ថា: ដរាបណានៅមានព្រះម្ចាស់សួគ៌ដរាបនោះនៅមានចំណាយមានព្រលឹងស្ពា ... ។ ពួកនេះគេយល់ថា: គំនិតនេះហើយ គឺរួមសម្បននិយម, គឺប្រជាធិបតេយ្យមនុស្សនិយម, គឺសត្តាវៈនិយម មិនទាន់ជឿផ្តេសផ្តាសតាមគំនិតយល់សប្តិ ។ ។

ទស្សនវិទូល្បីឈ្មោះ សេក-និ-សុបស្តិ៍ នៅស្ទូរៀកបាន ធ្វើអត្ថាធិប្បាយថា: « លទ្ធិអត្ថិភាពមនុស្សនិយម » គឺជាលទ្ធិ សម្ភារៈនិយម ១ បែបថ្មី ប៉ុន្តែពុំបានជំរុញទៅខាងបរមត្ថ សាស្ត្រ (Métaphysique) គឺព្រោះពួកនេះគ្មានសមត្ថភាពគ្លាប រវាងសតិបញ្ញាទៅនឹងចលនារបស់សត្វ... ។

ពួកអ្នកដើរតាមចលនាមានទិដ្ឋិយមនេះ ចាត់ទុកបរិវេណនៅ ក្នុង Saint Germains des Prés ជាខ្លាំង គាត់ច្រើនតែពួកយុវជន ស្រីប្រុសដែលពុញព្រាន់នឹងជីវិត, ភិតភ័យនឹងសង្គ្រាម. គេបបួលគ្នាស៊ីផឹក, លេងសើច, លាក់សើយ... ឲ្យអស់ចិត្ត ទៅក្នុងជីវិតបានមាន ។

គេស្លៀកពាក់ហ៊ឺហា, ចង់ស្រីផឹកស្រា, រាំរោប, ប្រគប់ យប់ពាសកាលព្រើមព្យាបាយក្រឡុកគ្រប់យ៉ាង. ដើម្បីកព្រោក ប្រឆាំងនឹងសិល្បធម៌... ។ល។ ឥទ្ធិពលរបស់គេកាន់តែរីក ចំរើនឡើងយ៉ាងខ្លាំងរហូតទៅដល់ទីក្រុង ញូវ-យ៉ក, ឡុងដុង

ទីនីវែបលហៀក ... ៗ កំណាព្យរបស់លោក ប្រេវែរ (Prévert) ត្រូវបានគេសរសើរ សំឡេងចម្រៀងនាង Julliette greco ត្រូវបានគេលើកតម្កើង ... ៗ ប៉ុន្តែចលនាអក្សរសាស្ត្រផ្ទ សម្ភារៈនិយមបែបលទ្ធិអត្ថិភាពនិយមនេះ ក៏មានចរិតពុករលួយ លើកតម្កើងការបំណាមពេក ព្រោះបាត់សក្តិមនុស្ស. ពលកម្ម អនុវត្ត នៅចុងបំផុត ក៏ត្រូវទទួលរងការពលនាអក្សរសាស្ត្រ សម្ភារនិយមបដិច្ចសមុប្បាទនៅ (Matérialisme dialectique) ។

# ចលនាអក្សរសាស្ត្រលោកិយសច្ចៈ Réalisme

អត្ថន័យ = អក្សរសាស្ត្រលោកិយសច្ចៈ គឺជាចលនាមួយមានទិដ្ឋាការសច្ចៈ គឺជាស្វែងរកការពិតឲ្យជួបពិតមែនៗ គេច្រើនយកចិត្តទុកដាក់ដល់ការគអន់ថយ ដែលជាគុណវិបត្តិរបស់មនុស្ស ។

ចលនាលោកិយសច្ចៈ ក៏មានចរិតប្រហាក់ប្រហែលគ្នានឹងពួកធម្មជាតិនិយមដែរ (Naturalisme) ប៉ុន្តែពួកធម្មជាតិនិយមគេមានប្រការពិសេសត្រង់ថា : គេស្វែងរកការពិតឲ្យជួបពិតមែន ប៉ុន្តែមានថែមភាគវៃកញ្ចក់វះកាត់ធ្វើការបែងចែកប្រៀបធៀប ...។

ពួកលោកិយសច្ចៈនេះគេយល់ថា :

– បើតាមគំនិតបុគ្គលនិយម គឺអត្តទត្ថកាត.

– បើតាមគំនិតប្រះលោមលោក គឺពុករលួយ

– បើតាមគំនិតបុរាណ (Classique) គឺហ៊ុំហាទាំងក្រៅ តែអត្ថសេរីរលួយ ... ។ ហេតុនេះពួកលោកិយសច្ចៈគេមានទស្សនៈថា : ពុំយល់ស្វែងរកការពិតគឺពិតដល់កម្រិតណា ចំពោះ

ពពួកមនុស្សពុនណា និយាយដើម្បីឲ្យ អ្វីខ្លះដែលត្រូវនិយាយត្រង់ៗ ឲ្យពិត អ្វីខ្លះដែលត្រូវបន្ថយបន្ថយ . . . ។ល។

បលនាលោកិយសច្ចៈ មានច្រើនប្រភេទអនុលោមទៅតាមបញ្ហានិងករណីនីមួយៗ ដែលស្ដែងឡើងដូចជា ៖

១- សច្ចៈបុគ្គលនិយម = និយាយអំពីតែការពិតរបស់បុគ្គលម្នាក់ៗ លើកតម្កើងឯកជន (បុគ្គលនិយម) ឲ្យដាច់ពីសង្គមរបស់មនុស្ស ។

២- សច្ចៈលោកិយ = និយាយដល់ការពិតរបស់លោក របស់សង្គមមនុស្ស មិនយកចិត្តទុកដាក់ដល់បុគ្គលម្នាក់ៗ ឬ ចាប់មនុស្សម្នាក់ៗ ឲ្យតាមវិធានរបស់លោក ។

៣- សច្ចៈស្វារត្ថ = មើលតែទាំងអស់ពេញទោសៀមមួយកន្លែងមិនប្រែប្រួល គ្មានស្មារតីតស៊ូដើម្បីជាមោទ, គេទុកដូចជាជាផ្ទាំងរូបអ្នកនិពន្ធណាដែលមានគំនិតការពារ

៤– សច្ចៈពាក់កណ្ដាល = និយាយពីការពិត ប៉ុន្តែកាប់បញ្ហាមិនបានអស់ មិនយល់ពីការប្រែប្រួលនៃធម្មជាតិ មិនយល់មានសមាសភាពច្រើន ដែលគាប់ផ្សំឲ្យបានជាសភាវៈអ្វីមួយបានមានទៅក្នុងលោក, ក្នុងសង្គម, ក្នុងចក្រវាឡ ... ។

៥– សច្ចៈចិត្តសាស្ត្រ = សំដៅតែផ្នែកខាងចិត្ត ខាងអារម្មណ៍របស់មនុស្ស យកចិត្តជាធំបំផុត ទាត់ចោលសម្ភារៈខាងក្រៅដែលជាហេតុបណ្ដាលចិត្ត ទាត់ចោលពលកម្ម ទាត់ចោលឥទ្ធិពលនៃសង្គមក ... ។

៦– សច្ចៈជីវភាព = សំដៅតែពីរឿងរស់នៅរាល់ថ្ងៃការបានមានទៅក្នុងបច្ចុប្បន្ន ... មិនទទួលដឹងពីហេតុផលដែលមានពីមុនមក និងទៅអនាគត ... ។

៧– សច្ចៈលាយធុន = យកចិត្តទុកដាក់សំដៅផលការរស់នៅរបស់នាយទុន អ្នកមានវណ្ណៈខ្ពង់ខ្ពស់ .. នៅក្នុងសង្គមជាន់ដើម ។ ឃើញការស្ងៀមស្ងៀន, ឬឃើញការល្អគាស់

ពេលឧបាសយកើតមានការព្រួយបារម្ភ  ហេតុការក្តៅក្រហាយ សង្វេគ ... ។

<u>៨– សត្វៈអ្នកមាន =</u>  យកចិត្តស់ក:ហេតុស្រាយ ជីវភាពរស់នៅរបស់ពួកអ្នកមាន ក្ដុមិក ពន្លិយប្រើបាវព្រាវ កាយទុក្ខជេរប្រមាយខ្ញុំកំដរ ...

<u>៩– សត្វៈប្រជាការ =</u> សំគំនិយាយអំពីជីវភាពក្រខ្សត់ របស់វណ្ណៈស្មូរ: (កម្មករ + កសិករ) ប្រជាជនពលករ ... ដែលគិតពុំនកស្ទើរនៅក្នុងជីវិតដើម្បីរកសេចក្តីសុខរបស់ខ្លួន ... ។

<u>១០– សត្វៈធាំនស្រុក =</u> ចំប្រើនសំដែងឡើង ដោយ ចស្ស្រមឆ្ងៀវទៅហើយទូលំទូលាយរបស់ខ្លួន  ចំពោះការវិវត្តន៍ជឿនលឿនទាន់ស្រុករបស់សង្គមកំប៉ុជារបស់មនុស្សជាតិទូទៅ ... ។

# ចលនាអក្សរសាស្ត្រសង្គមនិយម

យកលទ្ធិសភាវនិយមបដិវត្តសម្បុរប្លាវ ឬលទ្ធិសភាវនិយមប្រវត្តិសាស្ត្រជាមូលដ្ឋានក្នុងការតែងនិងរិះគន់ ឬក្នុងការនិពន្ធរឿងកំណាព្យទាំងអស់ ។

អក្សរស គឺយកស្មារតីវិញ្ញាណៈធ្វើជាមូលដ្ឋានឱ្យការចលនារបស់ក្រុមនិពន្ធសកម្ម ។

គោលបំណងគឺដឹកនាំមនុស្សឱ្យទៅកាន់លទ្ធិសង្គមនិយម និងរួមបញ្ចូលនិយមអន្តរជាតិ ក្រោមការដឹកនាំរបស់គណៈបក្សពលករនិងកម្មករ . . . ។

មធ្យោបាយសំខាន់ គឺដាក់នយោបាយឃោសនាឡើងជួរមុខ ក្នុងការចលនាមនុស្សបំរើផលប្រយោជន៍របស់សង្គម ។ ផ្នែកសិល្បៈក៏ដូចជាផ្នែកគំនូរចម្លាក់ផ្សេងៗ ត្រូវបំរើគោលបំណងនយោបាយជាដាច់ខាត ។

ផ្នែកសង្គមនិយមគេយល់ថា: អក្សរសាស្ត្រគឺជាមធ្យោបាយ

សម្រាប់ឃោសនា, សម្រាប់បំរើសង្គម ... មិនត្រូវឲ្យព័ងមាន នៅដាច់ពោយឡែកពីសង្គមមនុស្សបានទេ ធ្វើបានបែបនេះ ទើបហៅជាអក្សរសាស្ត្រមានប្រយោជន៍ ... ។ល។

# អក្សរសាស្ត្រនិមិត្តរូបារម្មណ៍ Symbolisme.

អត្ថន័យ = ចលនាអក្សរសាស្ត្រនិមិត្តរូបារម្មណ៍មាននិតិការស៊ើបស្រាវទៅក្នុងចិត្តថ្លើម ឬ មនោសញ្ចេតនាមនុស្សយ៉ាងលាក់លៀមស្ងាត់កំបាំងដោយនិមិត្តរូបផ្សេងៗ មកប្រៀបធៀបជាឧបមា... ។

បញ្ញោបាយ = មានការលំបាកច្រើនក្នុងការសំដែងលាតត្រដាង. ត្រូវប្រមូលឲ្យអស់នូវសមត្ថភាពសិល្បៈដើម្បីការសំដែងជ័យជំនះ ។

ចោលអស់នូវបណ្ដាបែបបទពីដើម ប្រើវិធីថ្មី គន្លងថ្មី បែបបទ (Style) ថ្មីដើម្បីលាតត្រដាងឲ្យបាននូវការប៉ះប្រាជ្ញារបស់សតិអារម្មណ៍ ។

ភ្លេងតន្ត្រីមាននាទីយ៉ាងសំខាន់នៅក្នុងចលនានេះ នៅក្នុងការនិពន្ធនីមួយៗ P. Verlaine និយាយថា : « ភ្លេងតន្ត្រីមុន, ហើយភ្លេងតន្ត្រី បន្ទាប់មកគឺនៃភ្លេងតន្ត្រីទៀត » ៗ និយាយបែបនេះ

ពិបាកយល់ណាស់ ប៉ុន្តែយើងត្រូវមានទស្សនថា : ផ្សេងគ្រឿងក៏នាំឲ្យមនុស្សចាប់អារម្មណ៍ហើសណាស់ មានចរិតផ្ទាល់ផង ... ។ និយាយមួយបែបទៀតថា : អត្ថបទកវីពលនានិមិត្តរូបារម្មណ៍មានការពិបាកយល់ច្រើនចំពោះអ្នកអាន ប៉ុន្តែបើយើងអានមានបែបបទ (ធ្វើបទ) ទៀនចុះ, ធ្វើឲ្យមានពណ៌សម្បុរខុសៗគ្នា យើងអាចយល់បានមួយភាគយ៉ាងងាយដែរ ហើយបន្ទាប់មកយើងត្រូវប្រឹងធ្វើការសិក្សាដើម្បីយល់ថែម ... ។

ដើម្បីឲ្យអ្នកអានកំណាព្យ ឬ អត្ថបទយល់បានមួយបន្តិច ៗ (កុំឲ្យយល់តាំងស្រុងតែម្តងទៅក្តី) តាមអក្សរនិងភាពឃ្លាមួយៗ អ្នកនិពន្ធ មុននឹងនិពន្ធរឿងអ្វីមួយ ត្រូវបំបាត់ចោលបីភាគបួននៃលក្ខណៈសភាវៈនោះដើម្បីនាំឲ្យអ្នកអានមានការពិចារណារករកដោយខ្លួនឯង ។ ជាពាក្យលោក S. Mallarmé ។

ចលនានិមិត្តរូបារម្មណ៍ ក្នុងពេលក្រោយមកបានក្លាយទៅជាសម្ងាត់ស្មុគស្មាញគ្មានគេយល់ឃើញ (Hermétique) ហើយគេចាប់

ទៅជាមិនពិតទៀងទាត់ទៅវិញ (Surnaturalisme) ។

និយាយសង្ខេបទៅចលនានិមិត្តរូបារម្មណ៍មានបរិកសិល្បៈ ដើម្បីសិល្បៈ មិនមែនសិល្បៈដើម្បីបំរើជីវភាពមនុស្ស បំរើ-សង្គមមនុស្សទេ ... ។

# ការសង្ស័យចំពោះអក្សរសាស្ត្រខ្មែរ

ក្នុងការនិយាយពន្យល់អក្សរសាស្ត្រខ្មែរមួយផ្នែកខាងបាលីនា ព្រហ្មញ្ញនិយមនេះ យើងច្រើនតែជួបនឹងពាក្យដែលយល់មិនច្បាស់នូវពាក្យមួយម៉ាត់ ដែលគេហៅថា «អវតារ» ។ ឧទាហរណ៍ដូចជា ព្រះរាមជាភូអគ្គនារាយណ៍អវតារ ... ។ល។ តើអវតារនេះ វាមានឫសគល់យ៉ាងណាទៅ ?

នៅក្នុងបណ្ណាវណ្ណកម្ម ដែលជាចលនាអក្សរសាស្ត្រផ្នែកព្រហ្មញ្ញនិយម ព្រះវិស្ណុ (ព្រះនារាយណ៍) ជាអ្នកមានតួនាទីបង្កើតលោក មានតួនាទីរក្សាលោកនិងការពារសភាវៈល្អ និយាយរួមបើយើងរកបើកគម្ពីរវេទនៃវប្បធម៌របស់ជនអារ្យនៅប្រទេសឥណ្ឌាវិញ ... ។ ព្រះវិស្ណុនេះហើយដែលគេទុកជាអ្នកការពារសាសនាព្រហ្ម ផ្ចាញ់ផ្ចាលសត្រូវ[illegible]បៀតបៀនហើយជាបុត្ររបស់ព្រះបរព្រហ្ម ។ .

បើព្រះវិស្ណុជាអ្នកបង្កើតលោក ក្នុងលោកតាំងពីដើមក៏តែងតែមានសភាវៈល្អនិងអាក្រក់ជាមួយគ្នា ហេតុដូច្នេះ បាន

សេចក្តីថា ព្រះវិស្ណុបង្កើតសភាវៈល្អនឹងអាក្រក់ព្រមជាមួយគ្នា ។ ក្នុងនាទីការពារសភាវៈល្អ បើសិនណាជាព្រះវិស្ណុបណ្តោយទុក ឲ្យសភាវៈអាក្រក់ពុករុកធ្វើបាបសភាវៈល្អនោះ បានសេចក្តីថា ព្រះវិស្ណុនេះមានអយុត្តិធម៌នៅក្នុងខ្លួន ហើយម្យ៉ាងទៀតក្នុង លោកនេះក៏នឹងក្លាយទៅជាលោកពោរពេញទៅ ដោយសេចក្តីអយុត្តិធម៌ថែមទៀតផង ហេតុនេះព្រះវិស្ណុត្រូវមានភារៈការពារ សភាវៈល្អ ផ្ចាញ់ផ្ចាលសភាវៈអាក្រក់វិញ ។

ក្នុងនាទីបង្កើតលោកទាំងមូលនៃព្រះវិស្ណុ ក្នុងនាទីផ្ចាញ់ ផ្ចាលសភាវៈអាក្រក់ដើម្បីការពារសភាវៈល្អ នៃព្រះវិស្ណុទៀត... ដូច្នេះយើងឃើញថាក៏មានការព្រួយនៅក្នុងគំនិតព្រះវិស្ណុ ហើយ ម្យ៉ាងទៀត ក៏ដូចជាមនុស្សសាមញ្ញផង ក្នុងភារៈរបស់ខ្លួនមុន បង្កើតមុនបំផ្លាញ .... ។

ដើម្បីកែប្រែភារៈរបស់ព្រះវិស្ណុ ( យួនចិនច្រើនហៅថា ព្រះក្វាន់-ឥុម គឺព្រះវៃ ) មានបរិតក្កសាស្ត្រសាមញ្ញក្នុង

ការបំផ្លាញសត្វអាក្រក់ដែលខ្លួនបង្កើតនោះ ព្រះវិស្ណុត្រូវកាឡាខ្លួនជាសត្វផ្សេងៗ មកផ្លាញផ្លាល វិធីកាឡាខ្លួននេះហើយដែលគេហៅថា « អវតារ » ដូចជាពាក្យថា នារាយណ៍អវតារ ... ។ល។

ពាក្យថានារាយណ៍អវតារ គឺជាព្រះនារាយណ៍កាឡាខ្លួនមកជាសត្វផ្សេងៗឲ្យខុសពីតួរព្រះនារាយណ៍ (វិស្ណុ) ដើម្បីប្រតិបត្តិការៈអ្វីមួយ ដូចជាផ្លាញផ្លាលសត្វអាក្រក់ជាដើម...។

បើតាមរឿងពីដើម ព្រះនារាយណ៍កាឡាខ្លួនច្រើនលើកច្រើនគ្រាណាស់ ដើម្បីទប់ទល់សត្រូវការពារសត្វល្អមានហេតុទៅដល់រាប់ពាន់ដងដែរ ប៉ុន្តែជាធម្មតាគេច្រើននិយាយតែ ១០ គ្រាទេ ដូចជា: « នារាយណ៍ទសាវតារ »

---

## នារាយណ៍ទសាវតារ (ព្រះនារាយណ៍កាឡាខ្លួន ១០ គ្រា)

ក្នុងរឿងនារាយណ៍ទសាវតារ គេនិយាយថាព្រះនារាយណ៍កាឡាខ្លួន ១១ ដង ក្នុងកិច្ចការការពារគម្ពីរវេទ ការពារសាសនា

ព្រហ្មទីនសភាវៈល្អដោយមានរឿងមួយ ៗ យកមកបញ្ជាក់ដូចតទៅ រឿងជាតកផ្នែកពុទ្ធនិយមអំពីទីនៃផែនដី ៖

១- មត្យាវតារ កាលជាត្រី (សម្លាប់យក្សហៃគ្រីពការពារវេទ)

២- កុម្មាវតារ -"- ជាអណ្តើក (ក្បូរទឹកអម្រឹត)

៣- វរាហាវតារ -"- ជ្រូកព្រៃ (សម្លាប់យក្សហិរញ្ញាក្ស យកសមុទ្រមកវិញ)

៤- នរសិង្ហាវតារ -"- មនុស្សពាក់កណ្តាលសិង្ហពាក់កណ្តាល (សម្លាប់យក្សពិកាឞ)

៥- វាមនាវតារ -"- ព្រាហ្មណ៍តឿ (ត្រីវិក្រមដណ្តើមត្រៃលោក)

៦- បរសុរាមាវតារ -"- ព្រាហ្មណ៍កាន់ពូថៅ

៧- រាមចន្ទ្រាវតារ -"- ព្រះរាមចន្ទ្រ (ក្សត្រសុរិយវង្សក្នុងរឿងរាមកេរ្តិ៍)

៨.- គ្រឹស្ណាវតារ ការចុះជាស្តេចក្រឹស្ណា (ក្សត្រចន្ទ្រ វង្សក្នុងរឿងមហាភារតយុទ្ធ)

៩– ពុទ្ធាវតារ – „ ព្រះពុទ្ធសមណគោតម

១០– កាល់រក្យាវតារ – „ – ព្រះកល្កិ (ដែលនឹង មានក្នុងអនាគតនៅចុងកលិយុគនេះ) ។

ទសជាតក៍ (១០ រឿង)

១– តេមិយជាតក កសាងបំពេញនេក្ខម្មបារមី (គឺ ការចាកចេញបួស(ស្រឡះពីកាមសោភ័ណ)

២– ជនកជាតក កសាងបំពេញវីរិយបារមី (គឺការ កាន់ខ្ជាប់ខ្ជួនសេចក្តីព្យាយាម)

៣– សុវណ្ណសាមជាតក កសាងបំពេញមេត្តា បារមី (គឺការរាប់អានសព្វសត្វគ្មានរើសអើង)

៤– នេមិរាជជាតក កសាងបំពេញអធិដ្ឋានបារមី (គឺការតាំងចិត្តរកឲ្យឃើញការពិត)

៥– មហោសថជាតក កសាងបំពេញបញ្ញាបារមី (គឺការធ្វើឲ្យប្រះដ៏មានបញ្ញាដឹងរកសេចក្តីពិតក្នុងលោក...)។

៦– ភូរិទត្តជាតក កសាងបំពេញសីលបារមី (គឺការរក្សាឬគមខ្លួនឲ្យបាននូវបរិសុទ្ធល្អដល់កាយវាចាចិត្ត...)។

៧– ចន្ទកុមារជាតក កសាងខន្តីបារមី (គឺការរក្សាសេចក្តីអត់ធន់អំណត់ឲ្យខ្លាំងមាំមួន)។

៨– នារទជាតក កសាងបំពេញឧបេក្ខាបារមី (គឺតាំងចិត្តជាកណ្តាលព្រងើយកន្តើយ ចំពោះសភាវៈទាំងអស់)។

៩– វិធុរជាតក កសាងបំពេញសច្ចៈបារមី (គឺការកាន់ឲ្យខ្ជាប់ខ្ជួននូវពាក្យសំដីពិតប្រាកដ)។

១០– វេស្សន្តរជាតក កសាងបំពេញទានបារមី (គឺ...

គឺការលះបង់ទ្រព្យសម្បត្តិ ដាក់ទានដល់អ្នកដទៃដូច គ្មានកើសមុទ្រ ) ។

ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធញាណ គ្រប់ពុទ្ធបេក្ខទាំងឡាយ (ពុទ្ធង្កុរ) ត្រូវតែកសាងឱ្យបានបារមីទាំងនេះ ហេតុនេះហើយ បានជាយើងឃើញនៅក្នុងចលនាអក្សរសាស្រ្តពុទ្ធនិយមខ្មែរយើង មានជាតកជាច្រើនរឿងដែលនិទានអំពីជាតិព្រះពោធិសត្វទ្រង់យោនយកកំណើតជាសត្វផ្សេងៗ ដើម្បីកសាងសន្សំឱ្យបានបារមីទាំង ១០ នេះ ពីព្រោះបារមីនីមួយៗ មានចែកចេញជា ៣ ថ្នាក់ទៀត គឺថាថ្នាក់ធម្មតាមួយ ថ្នាក់កណ្តាលមួយ និងថ្នាក់ខ្ពស់មួយទៀត . . . ។ល។

---

សូមរង់ចាំអាន និងមានផ្សាយនៅពេលជិតនេះ

ពិសោធន៍ និងការល្បង និពន្ធប្រធាន៖

ចរិយា, ការគិតនិងផ្លូវទៅ

ដោយ ហ៊ុន – គឹមសៀ